ព្រឹត្តិបត្រ BULLETIN
លេខ០០១ | ឆ្នាំទី១ ខែមករា-មីនា ឆ្នាំ២០១៥
ព្រឹត្តិបត្រសម្លេងសហគមន៍ចេញផ្សាយដោយក្រុមអ្នកច្បាប់ និងសិទ្ធិមនុស្សដើម្បីការពារយុត្តិធម៌ជូនជនរងគ្រោះ

# សម្លេងសហគមន៍
SOMLENG SAHAKOM

ការផ្សាយរបស់គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE

# យុត្តិធម៌សម្រាប់អ្នកភូមិឡពាង ស្ថិតលើផ្លូវដ៏លំបាក !



ជម្លោះដីធ្លីដ៏រាំរ៉ៃរបស់ភូមិឡពាងដែលពីមុនមានប្រជាពលរដ្ឋចំនួន១០៨គ្រួសារដែលបានប្តឹងក្រុមហ៊ុនខេ.ឌី.ស៊ី(KDC)ថាបានរំលោភយកដីលំនៅដ្ឋាន និងដីស្រែចំការរបស់ពួកគាត់ចាប់តាំងពីឆ្នាំ១៩៩៦ ដែលដីនេះពួកគាត់រស់នៅកាន់កាប់អាស្រ័យផលតាំងពីឆ្នាំ១៩៨៣-៨៤មកម្លេះ  តែភាគីខាងក្រុមហ៊ុន

តទៅទំព័រទី 3

អធិប្បាយលេខនេះ:

## ការការពាររដ្ឋធម្មនុញ្ញ និង ការអនុវត្តន៍គោរពរដ្ឋធម្មនុញ្ញ

*រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលរបស់ប្រទេស ឬរដ្ឋ។ ប្រទេស ឬរដ្ឋនីមួយៗ តែងមានច្បាប់កំពូលជាគោល ដើម្បីអនុវត្តសម្រាប់ប្រទេសរបស់ខ្លួន ក្នុងគោលបំណងថែរក្សានូវស្ថិរភាព និងសណ្តាប់ធ្នាប់សង្គមក្នុងទិសដៅកសាងប្រទេស។*

ចំណែកនៅប្រទេសកម្ពុជាវិញ ក៏មានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនេះដែរ ប៉ុន្តែអ្វីដែលជាចំណុចសំខាន់នោះ គឺរដ្ឋធម្មនុញ្ញដែលត្រូវតែមានការអនុវត្តន៍ និងការពារពីរដ្ឋាភិបាលដែលជាអ្នកប្រតិបត្តិ ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងមានការគោរពស្មើភាពគ្នា វាជារឿងសំខាន់ណាស់នៅក្នុងប្រទេសកម្ពុជាដើម្បីឲ្យកម្ពុជាបច្ចុប្បន្នក្លាយជាប្រទេសនីតិរដ្ឋពិតប្រាកដ។

ដោយហេតុថាកម្ពុជាកំពុងតែមានការប្រទាំងប្រទើសគ្នា ដោយស្ថិតនៅក្នុងបរិយាកាសនយោបាយ

តទៅទំព័រទី 7

## មាតិកា

ការផ្តល់សម្បទានដើម្បីជាប្រយោជន៍ពលរដ្ឋ? ទំព័រ 8
ការវិភាគនយោបាយត្រូវការកម្រិតប៉ែបណា? ទំព័រ 9
អាដហុក ជាសមាជិកគណៈកម្មាធិការប្រព្រឹត្តកម្ម (CHRAC) បង្កើតកម្មវិធីដោះ...... ទំព័រ 10
ដាក់ទោសមន្ត្រីរាជការពាក់ព័ន្ធអំពើពុករលួយត្រូវគិតប្រាក់បៀវត្សស៊ីន ! ទំព័រ 11
ហេតុអ្វីត្រូវការចាំបាច់ធុរកិច្ចនិងសិទ្ធិមនុស្ស! ទំព័រ 12
ដកដី ផ្តល់ដី ជាជំនាញរបស់អ្នកនយោបាយ? ទំព័រ 14

# ព្រឹត្តិបត្រ សម្លេងសហគមន៍

សម្លេងសហគមន៍បង្កើតឡើងដោយក្រុមអ្នកច្បាប់ ស្មគ្រ័ចិត្តមិនរកកម្រៃការពារយុត្តិធម៌ជូនជនរងគ្រោះ។

**សម្លេងសហគមន៍**
គឺជាសម្លេងជនរងគ្រោះ ជាសាររបស់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ដើម្បីស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់ នឹងជាសម្លេងរបស់សហគមន៍ ជនក្រីក្រដែលទទួលរងនូវការរំលោភបំពានសិទ្ធិដោយពុំទទួលបានយុត្តិធម៌ក្នុងសង្គម ។

សម្លេងសហគមន៍ បន្លឺឡើងក្នុងគោលបំណងផ្តល់ព័ត៌មានដល់ថ្នាក់ដឹកនាំរដ្ឋាភិបាលអំពីភាពរងគ្រោះរបស់ប្រជាពលរដ្ឋដែលរងការគាប់សង្កត់ពីអ្នកមានទ្រព្យសម្បត្តិ និងមន្ត្រីអ្នកមានអំណាច។

**វត្ថុបំណងនៃការបោះពុម្ពព្រឹត្តិបត្រសម្លេងសហគមន៍**
សម្លេងសហគមន៍ គឺជាការផ្សាយរបស់ក្រុមអ្នកច្បាប់ និងសកម្មជនការពារសិទ្ធិមនុស្សពាក់ព័ន្ធការបញ្ចេញមតិ ទស្សនៈ យោបល់ ដែលជាសម្លេងសម្រាប់ប្រឆាំងនូវអំពើអយុត្តិធម៌ ដោយមធ្យោបាយអហិង្សាដែលផ្តោតទៅលើបញ្ហាដីធ្លី និងធនធានធម្មជាតិ។

**សកម្មភាព**
ពង្រឹងសង្គមស៊ីវិល ដីធ្លី និងធនធានធម្មជាតិ តាមរយៈនៃការបោះពុម្ពព្រឹត្តិបត្រសម្លេងសហគមន៍ រយៈពេល ៣ខែ ១លេខ ចំនួន ៣០០០ច្បាប់ ទៅ ១០០០០ច្បាប់ ដែលមានចំនួន ១៦ទំព័រ ពណ៌ ជាភាសាខ្មែរ។

ចែកផ្សាយព្រឹត្តិបត្រសម្រាប់សមាគម អង្គការដៃគូរ ជាពិសេសសហគមន៍ដែលទទួលរងផលប៉ះពាល់ ពីការរំលោភបំពាន។

មានយុទ្ធសាស្រ្ត ផ្តោតការយកចិត្តទុកដាក់ក្នុងកំរឹតមធ្យម នៃចំណេះដឹងទូទៅរបស់ប្រជាពលរដ្ឋ។

**ចាងហ្វាងការផ្សាយ**
លោក យី សុខសាន្ត ០១៦៨៣៥ ៥៩៧
០១២ ៨៨៣ ៩៨៩

**និពន្ធនាយក**
លោក សួន ប៊ុនសក្តិ ០៩២ ៣៨៤ ៣៥៧

**ជំនួយការនិពន្ធនាយក**
លោក អ៊ាង ពេជ្រ ០១២ ៨៤៨ ១២៤
លោក ស៊ឹង សែនករុណា ០៨៩ ៦៦៦ ៣១២

**បច្ចេកទេសកុំព្យូទ័រ**
លោក រដ្ឋា
លោក រតនា

**អ្នកឆ្លើយឆ្លងព័ត៌មាន**
សមាជិកគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា និងសមាជិកសហគមន៍។

តមកពីទំព័រមុខ

# យុត្តិធម៌សម្រាប់អ្នកភូមិឡពាង ស្ថិតលើផ្លូវដ៏លំបាក!




បានអះអាងដោយបំពានថាបានទិញដីពីអ្នកភូមិ និងបានរៀបចំឯកសារគ្រប់គ្រាន់មានប្លង់កម្មសិទ្ធិត្រឹមត្រូវ។ រីឯអ្នក ភូមិ បានចោទប្រកាន់ថាក្រុមហ៊ុនជាអ្នករំលោភយកដីពួកគាត់ដូចគ្នា។ ដោយសារតែការចោទប្រកាន់ និងការប្តឹង ផ្តល់ទៅវិញទៅមកអស់រយៈពេលជាង១០ឆ្នាំកន្លងមក នៅតែពុំមានដំណោះស្រាយ។ ដូចនេះអ្នកភូមិឡពាងដែលបានបាត់បង់ដីស្រែចំការ តាំងពីឆ្នាំ២០០៧ដោយមិនមានដីធ្លីសម្រាប់បង្កបង្កើនផល ព្រមទាំងតំណាងអ្នកភូមិមួយចំនួនរបស់ពួកគេត្រូវបានតុលាការចោទប្រកាន់ជាបន្តបន្ទាប់ ។

តាមការប្រមូលព័ត៌មានបានបង្ហាញថាប្រជាពលរដ្ឋបានកាប់ដីធ្លីដែលកំពុងមានទំនាស់តាំងពីឆ្នាំ១៩៨៣ រហូតមកដល់ពេលមានទំនាស់ បន្ទាប់ពីមានឈ្មួញចូលមកទិញដីក្នុងឆ្នាំ១៩៩៦ ដោយមានអាជ្ញាធរមូលដ្ឋានមានលោកមេភូមិ មេឃុំ និងមន្ត្រីមូលដ្ឋានក្នុងតំបន់នោះជាអ្នករៀបចំដើរទិញដីឲ្យក្រុមហ៊ុនដោយសហការណ៍ជាមួយឈ្មួញ(អ្នកគួកជេរ)។ នៅក្នុងការរៀបចំដី អ្នកភូមិបានអះអាងថា មានការបង្ខិតបង្ខំ ការក្លែងបន្លំឯកសារគាបសង្កត់ឲ្យប្រជាពលរដ្ឋលក់ដីក្នុងតម្លៃថោក (បើមិនលក់ក៏ត្រូវរឹបអូសយកដីដោយទទេដែរ)។

ប្រជាពលរដ្ឋមួយចំនួនបានលក់ដីក្នុងនោះអ្នកខ្លះបានលក់ដីរបស់ខ្លួនមួយចំនួន នឹងអ្នកខ្លះមិនបានលក់ដីទាល់តែសោះ។ ក្រោយពីបានទិញដីរួចហើយ ឈ្មួញដីបានសហការជាមួយមន្ត្រីមូលដ្ឋានគឺមានលោក **ថៃ ហ៊ី** ជាមេភូមិតាជេស, ឈ្មោះ **ហួត វ៉ាន់ថន** មេឃុំតាជេស បានជីកប្រឡាយហ៊ុំព័ទ្ធដីធ្វើឲ្យប៉ះពាល់ដីប្រជាពលរដ្ឋមួយចំនួនដែលមិនបានលក់។ ដោយសារហេតុនេះហើយ ក្នុងឆ្នាំ២០០១មានប្រជាពលរដ្ឋប្រមាណ១៩គ្រួសារ បានដាក់ពាក្យប្តឹងឈ្មោះថៃ ហ៊ី មេភូមិតាជេស, ឈ្មោះ **ហួត វ៉ាន់ថន** មេឃុំតាជេស, ទៅស្ថាប័នអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង (តែពុំមានការចាត់វិធានការឬធ្វើការដោះស្រាយទេ) នៅចុងឆ្នាំ២០០៦មានប្រជាពលរដ្ឋចំនួន២៣៦នាក់បានផ្តិតមេដៃប្តឹងឈ្មោះ **ថៃ ហ៊ី** នេះដដែលពីបទល្មើសថាបាន «ជីកប្រឡាយហ៊ុំព័ទ្ធយកដី, ដែលប្រជាជនមិនបានលក់, បង្ខំឲ្យរុះរើលំនៅដ្ឋាន និងបង្ខំឲ្យផ្តិតមេដៃប្រគល់ដីឲ្យទៅក្រុមហ៊ុន» ប៉ុន្តែការប្តឹងផ្តល់របស់ប្រជាពលរដ្ឋក៏ពុំបានទទួលនូវការដោះស្រាយទាល់តែសោះរហូតមកដល់ពេលនេះ។

ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយការបាត់បង់ដីធ្លី ផ្ទះសំបែង ដីស្រែចំការ បានដាក់ពាក្យប្តឹងតវ៉ាជាបន្តបន្ទាប់ទៅសមត្ថកិច្ចមូលដ្ឋានទាំងថ្នាក់ខេត្ត និងថ្នាក់ជាតិ តែមិនមានស្ថាប័នជាតិណាមួយបានចេញមុខការពារប្រជាពលរដ្ឋ ឬធ្វើការដោះស្រាយជូនប្រជាពលរដ្ឋឡើយ។ ក្នុងរយៈពេលជាង១០ឆ្នាំនៃសកម្មភាពតវ៉ារបស់ប្រជាពលរដ្ឋ មិនទទួលបានលទ្ធផលនៃការដោះស្រាយទាល់តែសោះ ចំណែកដីធ្លីរបស់ពួកគេក៏ត្រូវបានបាត់បង់ទាំងស្រុង ដោយក្រុមហ៊ុនហាមមិនឲ្យអ្នកភូមិធ្វើស្រែចំការអស់ជាច្រើនឆ្នាំ ពោលគឺអាជ្ញាធរទាំងអស់នោះ ចេះតែធ្វើការគំរាមកំហែងអ្នក

ហ៊ានចេញមុខតវ៉ា និងជួយចូលរួមប្រឌិតបទល្មើសព្រហ្មទណ្ឌផ្សេងៗប្តឹងប្រឆាំងប្រជាពលរដ្ឋរងគ្រោះទៅតុលាការកំពង់ឆ្នាំងជាបន្តបន្ទាប់។

ចាប់តាំងពីមានទំនាស់មក យ៉ាងហោចណាស់ មានប្រជាពលរដ្ឋចំនួន**១៧នាក់** ត្រូវបានចោទទទួលរងនូវការចោទប្រកាន់ពីបទព្រហ្មទណ្ឌដោយតុលាការ ក្នុងចំណោមនោះតុលាការបានចាប់ខ្លួនប្រជាពលរដ្ឋដាក់ពន្ធនាគារចំនួន៦នាក់ដោយមិនមានកំហុស ផ្ទុយទៅវិញការទទួលខុសត្រូវជួយដោះស្រាយទំនាស់ដីធ្លីរបស់សមត្ថកិច្ចពុំដែលកើតមានឡើយ។ សព្វថ្ងៃនេះ ជីវភាព រស់នៅ ប្រកបដោយការភ័យខ្លាច និងការមិនយកចិត្តទុកដាក់ពីអាជ្ញាធរមូលដ្ឋាន ទើបពួកគាត់បង្ខំចិត្ត (ប្រជាពលរដ្ឋ)មួយចំនួនបោះបង់ចោលបណ្តឹងឈប់តវ៉ា នៅសល់ចុងក្រោយត្រឹមចំនួន**៦១គ្រួសារ** តែប៉ុណ្ណោះ ហើយតំណាងរបស់ពួកគេចំនួន**៥នាក់**កំពុងជាប់បណ្តឹងក្នុងតុលាការខេត្តកំពង់ឆ្នាំងនៅឡើយទេ ក្នុងនោះមានមន្ត្រីសិទ្ធិមនុស្សម្នាក់ផងដែរ។ បច្ចុប្បន្ននេះក្រុមហ៊ុននេះបានគ្រប់គ្រងដី និងធ្វើរបងហ៊ុំព័ទ្ធទាំងអស់ចំនួន**៦១២**ហិកតា ដោយយកដីទុកចោលនៅទំនេរហាមឃាត់អ្នកភូមិមិនឲ្យធ្វើស្រែ ដោយមិនទាន់មានការអភិវឌ្ឍន៍អ្វីទាល់តែសោះនៅលើដីនោះ។

តាមប្រវត្តិនៃដំណោះស្រាយដែលកើតមានកន្លងមក គឺបានគ្រាន់តែធ្វើឡើងដោយការអន្តរាគមន៍ និងអានុសាសន៍ពីលោកជំទាវ**ស៊ិន សេរី** (ក្រុមការងារចុះជួយគណៈបក្សប្រជាជនកម្ពុជា)ពីសម្តេចវីរៈជ័យថៅហ្វាវាំង**គង់ សំអុល** និងដោយចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេច**ហ៊ុន សែន** តែប៉ុណ្ណោះ គឺមិនទទួលបាននូវលទ្ធផលដោះស្រាយអ្វីទេ គ្រាន់តែធ្វើប្រជាភិថុតឃោសនាទាក់ទាញរកសម្លេងឆ្នោតឲ្យគណៈបក្សឆ្នាំ២០០៨ តែប៉ុណ្ណោះ។ ជាមួយនេះដែរ មានក្រុមលោក**សយ សុភាព** បានទទួលសេចក្តីទុកចិត្តពីនាយករដ្ឋមន្ត្រី ក៏បានចុះជួយរកដំណោះស្រាយដើម្បីជួយប្រជាពលរដ្ឋ ក៏មិនអាចធ្វើឲ្យភាគីទាំងពីរស្រុះស្រួលគ្នាឈានទៅដល់ដំណោះស្រាយណាមួយជូនប្រជាពលរដ្ឋបានដែរ។ ស្របពេលជាមួយគ្នានោះ យើងក៏សង្កេតឃើញ អាជ្ញាធរខេត្តក៏មិនដែលចាត់វិធានការដើម្បីរកដំណោះស្រាយឲ្យប្រជាពលរដ្ឋទាល់តែសោះ ក្រៅអំពីបញ្ជូនកំលាំងប្រដាប់អាវុធទៅគំរាមកំហែងប្រជាពលរដ្ឋ ហាមឃាត់អ្នកភូមិមិនឲ្យទាមទារ តវ៉ាប្រឆាំងនឹងក្រុមហ៊ុនតទៅទៀត ពិសេសលោក **ទូច ម៉ារីន** ក្នុងឋានៈជាអភិបាល ខេត្តកំពង់ឆ្នាំង មិនដែលស្គាល់ភូមិឡពាងម្តងណាឡើយ។ លើសពីនេះ ក្រុមមន្ត្រីមូលដ្ឋានបានរៀបចំឯកសារតាមរយៈការឃុបឃិតគ្នា ជាមួយស្ថាប័នតុលាការក្នុងខេត្តនោះ បានយកច្នៃប្រឌិតឯកសារមិនប្រក្រតី មកធ្វើអំណះអំណាងនៅចំពោះមុខច្បាប់ដោយចោទប្រកាន់ប្រជាពលរដ្ឋថា បានរំលោភយកដីរបស់ក្រុមហ៊ុន ប៉ុន្តែឯកសារទាំងអស់នោះមិនបានដាក់ជូនរដ្ឋអំណាចមូលដ្ឋានណាទេតាំងពីឃុំរហូតដល់ស្រុក បន្ទាប់ពីក្រុមសិទ្ធិមនុស្ស មេធាវី និងក្រុមអធិការកិច្ចក្រសួងមហាផ្ទៃបានរកឃើញកន្លងមក ដូចនេះការស្វែងរកយុត្តិធម៌របស់អ្នកភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងគឺមានភាពទន់ខ្សោយទៅៗ ពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារតែគ្មានការជួយអន្តរាគមន៍ពីស្ថាប័នមូលដ្ឋានក៏ដូចស្ថាប័នថ្នាក់ជាតិ។ ភាពក្រីក្រ និងការភ័យខ្លាចបានដុតរោលរាលក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេឈានទៅរកភាពលំបាកវេទនាតោកយ៉ាកជាខ្លាំង ពីមួយថ្ងៃទៅមួយថ្ងៃ ជាពិសេស ដីធ្លីរបស់ពួកគាត់ក៏ត្រូវបានបាត់បង់ទាំងស្រុង តំណាងប្រជាពលរដ្ឋដែលចេញមុខតវ៉ាទទួលរងការចោទប្រកាន់ និងចាប់ដាក់ពន្ធនាគារ ធ្វើឡើងដោយក្រុមហ៊ុនដែលមានអំណាចឃុបឃិតគ្នាជាមួយអាជ្ញាធរមូលដ្ឋានប្តឹងមួលបង្កាច់បង្ខូចប្រជាពលរដ្ឋថាជាអ្នកប្រព្រឹត្តិអំពើល្មើសច្បាប់ផ្សេងៗ។ ដើម្បីទាមទារមកវិញនូវភាពយុត្តិធម៌ ក្រុមអ្នកភូមិក៏បានតស៊ូក្រាញននាលព្យាមយាមដាក់ពាក្យបណ្តឹងទៅតុលាការ ដោយសារតែគាត់សុខចិត្តលះបង់អាយុជីវិតដោយសារតែដីរបស់ពួកគាត់ និងសុំឲ្យមានការស៊ើបអង្កេត និងស្រាវជ្រាវដោយឯករាជ្យថា តើភាគីណាមួយជាអ្នកបានទៅរំលោភយកដី។

ការប្តឹងផ្តល់ករណីស៊ីវិលបែបនេះ គឺបានធ្វើច្រើនលើកច្រើនសារ ទៅតុលាការខេត្តកំពង់ឆ្នាំង តែដំណើរការមានការរអាក់រអួលជាបន្តបន្ទាប់ដោយតុលាការបានយកលេសគ្រប់បែបយ៉ាង ដើម្បីបដិសេធន៍បណ្តឹងពីអ្នកភូមិ ហើយទម្រាំបានដាក់ពាក្យបណ្តឹងនេះបាន ប្រជាពលរដ្ឋពិតជាជួបការលំបាកគ្រប់បែបយ៉ាង ដូចជាត្រូវបង់ពន្ធលើកម្មវត្ថុនៃបណ្តឹងនៃបណ្តឹងដើម្បីឲ្យតុលាការធ្វើដំណើរការរឿងនេះបានជាដើម។ វាពិតណាស់ការដាក់ពាក្យបណ្តឹង និងទទួលពាក្យបណ្តឹងគឺជាការងាយស្រួល តែសម្រាប់ការបំពេញកាតព្វកិច្ចបង់ពន្ធលើរឿងក្តីស៊ីវិលមួយនេះ គឺជាការពិបាកប្រជាពលរដ្ឋពុំមានលទ្ធភាពបង់ពន្ធនេះទេ។ ម្យ៉ាងវិញទៀតបើទោះជាច្បាប់នេះផ្តល់ឆន្ទានុសិទ្ធិទៅចៅក្រម សម្រាប់ជួយសង្គ្រោះបណ្តឹងក៏ដោយក៏ផលវិបាកនៅតែប្រឈមចំពោះជនក្រីក្រដដែល ព្រោះទាំងនេះបើមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ដោយពុំមានការរើសអើងនោះវាជាការងាយស្រួលទេ តែសម្រាប់អាជ្ញាធរភូមិឃុំស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងជាអ្នកភូមិឡពាងវិញ ឲ្យតែបានលឺថាអ្នកភូមិនេះប្តឹងក្រុមហ៊ុនខេឌីស៊ី ពុំមានអាជ្ញាធរណាមួយហ៊ានចេញមុខទៅបញ្ជាក់ពីភាពក្រីក្រតោកយ៉ាករបស់ប្រជាពលរដ្ឋឡើយ។ ក្រុមអ្នកភូមិឡពាងបានបញ្ជាក់ថា គឺបានកាន់កាប់ដីធ្លីតាំងពីឆ្នាំ១៩៧៩រហូតមកទល់គ្នា និងឆ្នាំ១៩៩០លើទំហំដី១៤៥ហិកតា និង២៣អារ មានការទទួលស្គាល់ និងដឹងលឺពីអាជ្ញាធរមូលដ្ឋានប្រជាពលរដ្ឋបានដាក់ពាក្យសុំកាន់កាប់និងប្រើប្រាស់ដី អាជ្ញាធរអនុញ្ញាតឲ្យកាប់រុករានដីធ្វើស្រែចំការ និងផ្តល់ប័ណ្ណចុងសន្លឹក តាមគ្រួសារនីមួយៗ ការកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋមិនដែលអាក់ខាន ព្រមទាំងបង្កបង្កើនផលជាបន្តបន្ទាប់រហូតមក។

នៅឆ្នាំ១៩៩៦ ក្រុមឈ្មួញដើរទិញដីក្នុងនោះមានមេភូមិចំនួន៣ដើរទិញដីឲ្យឈ្មួញគឺមេភូមិឡពាងគឺលោក គុជ បៀន លោកឡុំ ឡីមេភូមិបឹងកក់ និងលោក ថៃ ហ៊ី ជាមេភូមិតាជេសក្នុងនោះមានមេឃុំតាជេស គឺលោក ហួត វ៉ាន់ថនជាអ្នកបានចូលរួមដែរ ក្នុងការទិញដីពីអ្នកភូមិនៅពេលដែលអ្នកភូមិបានបដិសេធន៍ និងស្បថស្បែថាពួកគាត់មិនបានលក់ដីនោះទៅឲ្យក្រុមហ៊ុនទេ។

ប្រជាពលរដ្ឋមានឯកសារសំអាងគ្រប់គ្រាន់ និងសាក្សីដឹងលឺថាពួកគេទាំងអស់មិនបានលក់ដីទៅឲ្យទៅក្រុមហ៊ុននោះទេក្នុងនោះមេភូមិតាជេសលោក **ថៃ ហ៊ី** លោក **ឡុំ ឡី** មេភូមិបឹងកក់ និង **ហួត វ៉ាន់ថន** មេឃុំតាជេស អ្នកទាំងបីនេះបានបំភ្លឺក្នុងលិខិតចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០១ និងលិខិតចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៦ ដែលបញ្ជាក់

អំពីទំហំដីដែលពួកគេបានទិញ។

ប្រជាពលរដ្ឋបានដាក់ពាក្យសុំជួយអន្តរាគមន៍ ជាច្រើនលើកច្រើនសារទៅស្ថាប័នថ្នាក់ខេត្ត និងថ្នាក់ជាតិ ពិសេសស្ថាប័នតុលាការដែលបានធ្វើឲ្យបាត់សំណុំរឿងរបស់ប្រជាពលរដ្ឋ ដោយមិនបានបញ្ជាក់មូលហេតុ។ គិតចាប់តាំងពីកើតមានទំនាស់មក ភាគីខាងក្រុមហ៊ុនបានប្តឹងប្រជាពលរដ្ឋយ៉ាងហោចណាស់មាន**១៧នាក់**ទៅស្ថាប័នតុលាការ ក្នុងនោះជាប់ពន្ធនាគារចំនួន**៦នាក់** តែដោះលែងដោយរួចទោស**៥នាក់** និងកំពុងជាប់ក្នុងពន្ធនាគារចំនួន**១នាក់**(ឈ្មោះ**សរ សុង** ពីបទប៉ុនប៉ងមនុស្សឃាដមិនបានសម្រេច និងបង្ករបួសស្នាម ដែលតុលាការខេត្តកំពង់ឆ្នាំងសម្រេចផ្តន្ទាទោសគុកចំនួន១១ឆ្នាំ) មានការព្រួយបារម្ភជុំវិញបញ្ហាឈ្មោះសរ សុង ដែលអាចទទួលរងនូវអំពើអយុត្តិធម៌ពីក្រុមសមត្ថកិច្ច ពិសេសតុលាការបានធ្វើការសម្រេចចោទប្រកាន់ និងផ្តន្ទាទោសដោយខ្វះការស៊ើបអង្កេតត្រឹមត្រូវ ពុំមានភស្តុតាងច្បាស់លាស់ ពិសេសភាពមិនប្រក្រតីនៃឯកសារមួយចំនួន ក៏នៅតែសម្រេចផ្តន្ទាទោសជនរងគ្រោះដាក់ពន្ធនាគារទាំងអយុត្តិធម៌។ ក្រៅពីនេះនៅមានតំណាងជាស្ត្រីម្នាក់ទៀតឈ្មោះ **អ៊ុន ទុំ** ត្រូវក្រុមហ៊ុនប្តឹង ហើយតុលាការចាប់ដាក់ចំនួន១៨ខែផងដែរ ក្រោយមកអ្នកស្រីក៏ត្រូវបានដោះលែងដោយអំនាចសាលក្រម អ្នកស្រីបានឲ្យកូនស្រីឈ្មោះ **អ៊ុន សុភី** ធ្វើការតវ៉ាបន្ត និងធ្វើជាតំណាងប្រជាពលរដ្ឋ ក្រុមហ៊ុនបានប្តឹងអ្នកស្រីទៅតុលាការរាជធានីភ្នំពេញ តុលាការនេះក៏បានចេញដីកាចាប់ខ្លួន **អ៊ុន សុភី** បន្តទៀត តែពេលនោះគាត់បានរត់គេចខ្លួនពីការតាមចាប់របស់តុលាការរាជធានីភ្នំពេញ។ ចំណែកសាលាដំបូងរាជធានីភ្នំពេញដដែលនេះ កាលពីថ្ងៃទី៤ កញ្ញា ២០០៩ បានផ្តន្ទាទោសមេភូមិឡពាង ឈ្មោះលោកស្រី **ទូច លី** ឲ្យជាប់គុក១៦ខែ និងផាកពិន័យជាប្រាក់ចំនួន៦លានរៀល ក្រោមបទចោទប្រកាន់ដោយមូលបង្កាច់ថា លោកស្រីបានក្លែងបន្លំលិខិតស្នាម ជុំវិញបណ្តឹងរបស់ប្រជាពលរដ្ឋ ចំនួន៧៧គ្រួសារប្រឆាំងនឹងក្រុមហ៊ុន KDC របស់លោកស្រី ជា ខេង ក្នុងរឿងទំនាស់ដីធ្លី។ បន្ទាប់ពីបានចេញពីពន្ធនាគារមកវិញអ្នកស្រីត្រូវបានបាក់ស្មារតី មិនហ៊ានធ្វើសកម្មភាពតវ៉ាទៀតឡើយ។ នៅចុងក្រោយនេះតំណាងប្រជាពលរដ្ឋ ពីរនាក់ផ្សេងទៀត និងមន្ត្រីសិទ្ធិមនុស្សសមាគម អាដហុកប្រចាំខេត្តកំពង់ឆ្នាំងម្នាក់ ក៏ត្រូវបានតុលាការខេត្តកំពង់ឆ្នាំងចោទប្រកាន់និងពិន័យជាប្រាក់ពីបទពីបទបរិហារកេរ្តិ៍ និងធ្វើឲ្យខូចខាតទ្រព្យសម្បត្តិក្រុមហ៊ុន ។

ជាង១០ឆ្នាំកន្លងមកនេះក្រុមអ្នកតវ៉ារង់ចាំការជួយដោះស្រាយពីអាជ្ញាធរ យ៉ាងហោចមានមនុស្សចំនួន២ស្លាប់ ដោយជម្ងឺអស់សង្ឃឹមនៅក្នុងទំនាស់ដីធ្លីនោះ។

កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១០ លោក សំ ច័ន្ទគា ជាបុគ្គលិក សមាគមអាដហុក និងជាអ្នកសម្របសម្រួលសមាគម អាដហុកប្រចាំខេត្តកំពង់ឆ្នាំង ត្រូវលោកហេង លុយ ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ឆ្នាំង បានចេញដីកាកោះហៅឲ្យចូលខ្លួនទៅសាកសួរ ថ្ងៃទី២៩/០៩/ ២០១០ ពីបទជាប់សង្ស័យថាបាន « **ផ្សព្វផ្សាយព័ត៌មានមិនពិត និងបរិហារកេរ្តិ៍** » រួមជាមួយឈ្មោះ ផេង រ៉ុ និងឈ្មោះ **រាជ សីម៉ា** ជាតំណាងប្រជាពលរដ្ឋភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ក៏ត្រូវបាន លោក **ហេង លុយ** ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ឆ្នាំងកោះហៅឲ្យចូលខ្លួន ថ្ងៃទី៣០/០៩/២០១០ ជាប់សង្ស័យពីបទ« **បរិហារកេរ្តិ៍ និងធ្វើឲ្យខូចខាតដោយចេតនា ដល់ផលប្រយោជន៍ក្រុមហ៊ុន**»។



សកម្មភាពរបស់ព្រះរាជអាជ្ញារង នៃសាលាដំបូងខេត្តកំពុងឆ្នាំង គឺធ្វើឡើងបន្ទាប់ពីមានការដាក់ពាក្យបណ្តឹងរបស់ឈ្មោះ **ថៃ ហ៊ី** តំណាងក្រុមហ៊ុនខេ.ឌី.ស៊ី ដែលមានជំទាវជា ខេង ជាប្រធានក្រុមហ៊ុន ត្រូវជាភរិយារបស់ឯកឧត្តមស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម បានប្តឹងចោទលោក **សំ ច័ន្ទគា** ថា បានផ្សព្វផ្សាយព័ត៌មានមិនពិតតាមរយៈវិទ្យុអាស៊ីសេរី កាលពី





ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង៨និង ៣០នាទីយប់ និងទាមទារសំណងខូចខាត និងជំងឺចិត្តចំនួន៤០,០០០,០០០ រៀល(សែសិបលានរៀល)។ លទ្ធផលចុងក្រោយនៃការប្ដឹងនេះលោកចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តកំពង់ឆ្នាំង លោក **សាន សុផាត** បានប្រកាសសាលក្រមសម្រេចនៅព្រឹកថ្ងៃទី២៥ ខែមករា ដោយតម្រូវឲ្យលោក **សំ ច័ន្ទគា** មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុកប្រចាំខេត្តនេះ បង់ប្រាក់ពិន័យចំនួន១លានរៀល និងប្រាក់សំណងទៅក្រុមហ៊ុន ខេ.ឌី.ស៊ី. អន្តរជាតិ ចំនួន **៣**លានរៀល។ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១០កន្លងទៅ តុលាការខេត្តកំពង់ឆ្នាំង ក៏បានចេញសាលក្រមសម្រេចឲ្យលោករាជ សីមា ប្រជាពលរដ្ឋនៅភូមិឡពាងចាញ់ក្ដីដើមបណ្ដឹងក្រុមហ៊ុន ខេ.ឌី.ស៊ី.នេះដែរ ដោយពិន័យជាប្រាក់២លានរៀល និងបង់ជំងឺចិត្ត ៨លានរៀលទៅឲ្យភាគីក្រុមហ៊ុន។ ករណីប្ដឹងផ្ដល់គ្នានេះ ក្រុមហ៊ុនមានចេតនាមិនចង់បានសំណងមានបានពីអ្នកភូមិទាល់តែសោះ គ្រាន់តែមានចេតនាមួយចង់បំបាក់ស្មារតីអ្នកភូមិកុំឲ្យតវ៉ាតែប៉ុណ្ណោះ **ពីព្រោះក្រុមហ៊ុនបានប្រកាសយកសំណងពីតុលាការដាក់ជូនកាកបាទក្រហម។**

ក្រុមហ៊ុនខេឌីស៊ី ដែលមានលោកជំទាវ**ជា ខេង** ជាប្រធាន លោកស្រីជាភរិយារបស់លោក**ស៊ុយ សែម** ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រួមជាមួយលោកមេធាវី **ផាត់ ពៅសៀង** (**ដែលទទួលសេវា**) ដែលមានឥទ្ធិពល និងអំណាច អាចធ្វើឲ្យអាជ្ញាធរមូលដ្ឋានខេត្តកំពង់ឆ្នាំងមួយនេះរុញរាមិនហ៊ានចាត់វិធានការតាមច្បាប់ដើម្បីការពារយុត្តិធម៌ជូនប្រជាពលរដ្ឋ និងធ្វើឲ្យមានភាពស្មុគ្រស្មាញគ្រប់បែបយ៉ាងដល់អ្នកភូមិ។

ភាពអន់ថយនៃការអនុវត្តន៍ច្បាប់របស់អាជ្ញាធរខេត្តកំពង់ឆ្នាំង បានធ្វើឲ្យអ្នកភូមិឡពាងបាត់បង់ដីធ្លីទាំង ស្រុង នេះជាកំហុសឆ្គងដ៏ធ្ងន់ធ្ងរមួយរបស់អាជ្ញាធរ។ អាជ្ញាធរខេត្តនេះ បានចាត់ទុកការទាមតវ៉ារបស់ប្រជាពលរដ្ឋទៅស្ថាប័ននានាទាំងថ្នាក់ខេត្ត និងថ្នាក់ជាតិ ពិសេសពាក្យបណ្ដឹងបានដាក់ជូនគណបក្សប្រឆាំង និងក្រុមសង្គម ស៊ីវិលនានាថាជាការប្រឆាំងឬជាការញុះញង់។ អាជ្ញាធរខេត្តនេះផងដែរបានទទួលស្គាល់ថា ក្រុមហ៊ុនមានលក្ខណៈស្របច្បាប់និងពិតជាម្ចាស់ដីត្រឹមត្រូវច្បាប់ បើទោះជាគ្មានឯកសារដាក់ដំកល់នៅតាមការិយាល័យមូលដ្ឋានរបស់ខ្លួនក៏ដោយ។ ខុសប្លែកពីប្រជាពលរដ្ឋដែលបានរស់នៅជាមួយអាជ្ញាធរមូលដ្ឋានអស់ទាំងនោះជាង៣០ឆ្នាំតែបែរជាមិនទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់របស់ប្រជាពលរដ្ឋទៅវិញ។

អាជ្ញាធរខេត្តកំពង់ឆ្នាំងបានព្រងើយកន្តើយ ធ្វើមិនដឹងមិនលឺចំពោះសម្រែកទាមទាររកយុត្តិធម៌របស់ប្រជាពលរដ្ឋភូមិឡពាងពួកគេអាចចូលរួមឃុបឃិតជាមួយក្រុមហ៊ុនក្នុងការបន្លំបន្លំឯកសារអំពីការលក់ទិញដី ព្រោះក្រសួងមហាផ្ទៃ បានធ្វើកោសល្យវិច្ច័យមេដៃលើលិខិតលក់ទិញដីដែលអាជ្ញាធរទទួលស្គាល់ បែរជាតុលាការខេត្តកំពង់ឆ្នាំងធ្វើឲ្យបាត់សំណុំរឿងទៅវិញ។

បច្ចុប្បន្ន នៅពេលដែលអ្នកភូមិឡពាង ធ្វើការតវ៉ា តស៊ូ ខ្លាំងក្លាមួយចំនួនបានសំណងពី ក្រុមហ៊ុន និងមួយចំនួនទៀតនៅតវ៉ាទាមទារដី ហើយពួកគាត់បាន បានដើរដាក់ញាតិ គ្រប់ស្ថាបន័រួចរាល់អស់ហើយរងចាំតែ ចំលើយប៉ុណ្ណោះ ដោយបច្ចុប្បន្ន កំពុងស្ថិតលើផ្លូវដ៏លំបាកសម្រាប់ស្វែងរកយុត្តធម៌៕



តមកពីទំព័រមុខ

# ការការពាររដ្ឋធម្មនុញ្ញ និងការអនុវត្តន៍គោរព រដ្ឋធម្មនុញ្ញ

មួយ ដែលមហាជន ប្រជាពលរដ្ឋ និងសង្គមស៊ីវិលកំពុងប្រើប្រាស់សិទ្ធិស្របច្បាប់ ដោយអនុវត្ត និងគោរពទៅតាមរដ្ឋធម្មនុញ្ញ តែរដ្ឋាភិបាលកំពុងតែប្រើប្រាស់ការការពាររដ្ឋធម្មនុញ្ញដោយកម្លាំងរដ្ឋាភិបាល។ តើហេតុអ្វីបានជាប្រទេសតែមួយមានច្បាប់កំពូលតែមួយបែរជាមានការប្រទាំងប្រទើសគ្នាយ៉ាងដូច្នេះ?

បើយើងក្រឡេកមើលទៅតួនាទីរបស់រដ្ឋ គឺរាជរដ្ឋាភិបាលត្រូវមានតួនាទីការពារ អនុវត្ត និងគោរពទៅតាមរដ្ឋធម្មនុញ្ញ ដែលវាជាការត្រឹមត្រូវមួយ ស្របទៅនឹងការប្រកាសរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនដែលឲ្យកងកម្លាំងប្រដាប់អាវុធទាំងអស់ ការពាររដ្ឋធម្មនុញ្ញនោះ ពីព្រោះរដ្ឋធម្មនុញ្ញជាច្បាប់កំពូលគ្របដណ្តប់ទៅលើច្បាប់ដទៃផ្សេងៗដែលការពារទ្រព្យសម្បត្តិឯកជនគឺជាកម្មសិទ្ធិដែលត្រូវទទួលបានការគោរពនិងការពារ ស្របតាមរដ្ឋធម្មនុញ្ញដូច្នេះទង្វើបែបនេះគឺជាការការពាររដ្ឋធម្មនុញ្ញនិងច្បាប់ផ្សេងៗទៀតពាក់ព័ន្ធនឹងការគោរពភាពជាម្ចាស់កម្មសិទ្ធិនេះ។ ចំពោះការការពារនេះគឺធានា និងទប់ទល់បាននូវរាល់ឧបាយកលនានាដែលប៉ុនប៉ងបំផ្លាញសន្តិភាព សន្តិសុខសង្គម ស្ថិរភាពនយោបាយ ភាពចលាចល ការប៉ុនប៉ងឲ្យមានអំពើហិង្សានិងភាពវឹកវរក្នុងសង្គម ដែលរដ្ឋអាចត្រូវចាត់វិធានការតាមផ្លូវច្បាប់បាន។

តែយើងត្រូវមើលទៅភាពត្រឹមត្រូវនេះផងថា តើវាមានហេតុផលដែលស្របទៅនឹងការគោរពតាមរដ្ឋធម្មនុញ្ញដែរឬទេ?

ភាពអូសបន្លាយនៃការជាប់គាំងនយោបាយគឺជាដើមចមដ៏សំខាន់មួយដែលជំរុញឲ្យកើតមានការទាមទារតាមរយៈការធ្វើកូដកម្ម បាតុកម្មរបស់កម្មករ កម្មករិនីរោងចក្រ អហិង្សា ដែលបណ្តាលឲ្យមានការបង្ក្រាប ពីរដ្ឋាភិបាលមកលើកម្មករ ដែលរដ្ឋាភិបាលអះអាងថាជាការការពាររដ្ឋធម្មនុញ្ញនោះ។ ដូច្នេះហើយទើបក្រសួងមហាផ្ទៃ ចេញនូវសេចក្តីប្រកាសព័ត៌មាន តាមរយៈប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក កាលពីដើមខែមករានៅខណៈដែលកងកម្លាំងរបស់រដ្ឋាភិបាលបានទៅបោសសម្អាតបាតុករគណបក្សសង្គ្រោះជាតិ នៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី៤ មករា ឆ្នាំ២០១៤ នោះថា«ការប្រមូលផ្តុំនានាបាននាំទៅដល់ការប្រើអំពើហិង្សាការបិទផ្លូវសាធារណៈ និងការបំផ្លាញទ្រព្យសម្បត្តិឯកជន និងសាធារណៈដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខសណ្តាប់ធ្នាប់សង្គម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ដើម្បីធានាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គមការធ្វើបាតុកម្មតាមរយៈការជួបប្រជុំជាសាធារណៈឬការដង្ហែក្បួននានា ត្រូវផ្អាកជាបណ្តោះអាសន្នរហូតដល់សភាពការណ៍សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានធានានិងវិលរកភាពប្រក្រតីឡើងវិញ»។

ជាមួយគ្នានោះដែរយើងក៏ឃើញការបង្ក្រាបរបស់កងកម្លាំងប្រដាប់អាវុធទៅលើកម្មករ និងការចាប់ខ្លួនសង្គមស៊ីវិលនៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ នៅរោងចក្រយ៉ាកជីន ការបង្ក្រាបថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤នៅតាមផ្លូវវែងស្រេង និងការបង្ក្រាបកន្លងមកទៅលើកម្មករSLនៅមុខវត្តស្ទឹងមានជ័យ។ល។ ដែលការបង្ក្រាបនោះបណ្តាលឲ្យមានមនុស្សស្លាប់និងចាប់ខ្លួនជាច្រើននាក់។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលឯកបក្សក៏បានបិទសិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងការជួបជុំគ្នា ឬធ្វើបាតុកម្មដោយសន្តិវិធី។ រាល់ការជួបជុំ ឬធ្វើបាតុកម្មតែងតែមានការបង្ក្រាបពីកងកម្លាំងរដ្ឋាភិបាលទោះបីធ្វើនៅទីលានប្រជាធិបតេយ្យឬនៅទីកន្លែងសាធារណៈផ្សេងៗទៀតក្តី។

ច្បាប់កម្ពុជា បានក្លាយជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយកាលពីថ្ងៃទី២៦ សីហា ឆ្នាំ១៩៩២។ មាត្រា៣១នៃរដ្ឋធម្មនុញ្ញ ធានាអនុសញ្ញានេះថាជាផ្នែកមួយនៃច្បាប់កម្ពុជា ហើយមាត្រាដទៃទៀតគូសបញ្ជាក់ឡើងវិញស្តីពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការធានាថាប្រជាពលរដ្ឋកម្ពុជា ទាំងអស់អាចអាស្រ័យនូវសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយរបស់ពួកគេតាមវិសាលភាពពេញលេញបំផុតតាមតែអាចធ្វើទៅបាន។ មាត្រា៣៧ នៃរដ្ឋធម្មនុញ្ញចែងថា សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធីត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់។

បើយោងទៅលើច្បាប់ដែលបានចែងការប្រកាសរបស់លោកនាយករដ្ឋមន្ត្រី ឲ្យកងកម្លាំងប្រដាប់អាវុធទាំងអស់ ការពាររដ្ឋធម្មនុញ្ញនោះគឺជាការប្រកាសដែលប្រឆាំងទៅនឹងរដ្ឋធម្មនុញ្ញទៅវិញទេពីព្រោះមន្ត្រីកងកម្លាំងប្រដាប់អាវុធបានធ្វើការបាញ់សម្លាប់មនុស្សក្រៅសំណាញ់ច្បាប់ នៅខណៈដែលកម្ពុជាមិនមានច្បាប់ដាក់ទោសប្រហារជីវិត។ ការហាមមិនឲ្យប្រជាពលរដ្ឋជួបជុំគ្នាឬធ្វើបាតុកម្មដោយសន្តិវិធី នៅខណៈស្ថានភាពនយោបាយជាប់គាំងដែលមិនស្ថិតនៅក្នុងភាពប្រកាសអាសន្ននោះជាដើម ដែលការហាមឃាត់មិនឲ្យមនុស្សជួបប្រជុំគ្នានេះមិនមែនជារឿងល្អទេវាជារឿងមួយស្មុគស្មាញប៉ះពាល់ដល់រដ្ឋធម្មនុញ្ញធ្ងន់ធ្ងរដែលរដ្ឋាភិបាលត្រូវថ្លឹងថ្លែងរវាងសិទ្ធិនៃការជួបជុំនិងបញ្ហាសន្តិសុខ ព្រោះកម្ពុជាមិនទាន់ស្ថិតនៅក្នុងភាពប្រកាសអាសន្ននោះឡើយ។

ដូចនេះសកម្មភាពរបស់រដ្ឋាភិបាលក្នុងការការពាររដ្ឋធម្មនុញ្ញនោះជាការបង្ហាញនូវក្តីបារម្ភរបស់រដ្ឋាភិបាលទៅវិញទេពីព្រោះរដ្ឋាភិបាលភ័យខ្លាចប្រជាពលរដ្ឋទាមទារឲ្យលោកចុះចេញពីតួនាទី ហើយអ្វីដែលជាកំហុសនោះគឺការការពាររដ្ឋធម្មនុញ្ញរំលោភទៅលើអ្វីដែលជាការអនុវត្ត និងគោរពទៅតាមរដ្ឋធម្មនុញ្ញ៕

# ការផ្តល់សម្បទានដើម្បីជាប្រយោជន៍ពលរដ្ឋ ?

*សម្បទានបើនិយាយពន្យល់តាមវចនានុក្រមខ្មែរ បានសេចក្តីថា«ការប្រគល់ឲ្យ ឬទ្រព្យដែលឲ្យដាច់» ដែលការពន្យល់នេះមិនពិបាកនឹងយល់ឡើយ ព្រោះបានបញ្ជាក់យ៉ាងច្បាស់លាស់ ប្រសិនបើយើងបន្ថែមពាក្យ ដី ផ្ទះ ស្រែ អណ្តូង។ល។ នោះនឹងមានន័យសេចក្តីគ្រប់គ្រាន់ ដែលអាចដឹងថា ការផ្តល់សម្បទានគឺដើម្បីជាប្រយោជន៍អ្វីមួយ ដល់បុគ្គលណាម្នាក់ ដល់សហគមន៍ដែលមានតម្រូវការចាំបាច់ ឬសហគមន៍ដែលមានផលប៉ះពាល់។*

ឧទាហរណ៍សហគមន៍នេសាទ ដែលទទួលរងផលប៉ះពាល់ពីការធ្វើនេសាទ ក្រោយពីមានការកែប្រែនយោបាយឡូត៍នេសាទមក ពួកគាត់បានទទួលផលប្រយោជន៍ ពីការរកទទួលទានពីផលនេសាទ ដោយមិនមានបញ្ហាជាមួយម្ចាស់ឡូត៍នេសាទឯកជនទៀតទេ។

ដូច្នេះយើងឃើញថាការផ្តល់សម្បទានដីសេដ្ឋកិច្ច ឬដីសម្បទានសង្គមកិច្ចក្តីសុទ្ធតែសំដៅលើប្រយោជន៍សម្រាប់ពលរដ្ឋក្រីក្រ ដើម្បីបានទទួលប្រយោជន៍ពីសម្បទានទាំងនោះ ដើម្បីលុបបំបាត់ភាពក្រីក្រ។ ប៉ុន្តែការផ្តល់សម្បទានដីសេដ្ឋកិច្ច នាពេលកន្លងមកនឹងរហូតដល់បច្ចុប្បន្ននៅតែមានបញ្ហា និងមិនបានផ្តល់ប្រយោជន៍អ្វីជាដុំកំភួនអ្វីសម្រាប់ប្រជាពលរដ្ឋក្រីក្រនោះឡើយ បែរជាផ្តល់បញ្ហាដល់ពួកគាត់បន្ថែមទៀតដូចជា៖បាត់បង់ផ្ទះសម្បែង ដីធ្លី ឬកាន់តែមានគម្លាតឆ្ងាយអំពីទីប្រជុំជន ទីបណ្តុំនៃចំណេះដឹង និងព័ត៌មានទៅវិញ។តើមកពីមូលហេតុអ្វី?ចម្លើយនេះអ្នកដឹកនាំពិតជាដឹងច្បាស់!

ការផ្តល់ដីដល់ក្រុមហ៊ុនអភិវឌ្ឍន៍ គឺជាការផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់ក្រុមហ៊ុនដែលមកបណ្តាក់ទុនរកស៊ីតាមរយៈការអភិវឌ្ឍន៍ ពោលគឺក្នុងន័យផ្តល់ ឬរកការងារឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អភិវឌ្ឍន៍មានការងារធ្វើតាមរយៈនៃការអភិវឌ្ឍន៍។

និយាយដល់ការអភិវឌ្ឍន៍ គឺជាការធ្វើឲ្យមានការរីកចម្រើនលូតលាស់តាមរយៈគម្រោងដែលរៀបចំឡើង និងស្របទៅតាមគោលនយោបាយអភិវឌ្ឍន៍ របស់រាជរដ្ឋាភិបាលផងដែរ។ គម្រោងអភិវឌ្ឍន៍នីមួយៗ ត្រូវរៀបចំការសិក្សាស្វែងយល់ អំពីផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ទាំងនោះ ដោយយោងទៅតាមអនុក្រឹត្យលេខ១៤៦អ.ន.ក្រ.បក ចុះថ្ងៃទី២៧ ខែ១២ ឆ្នាំ២០១២។

ប៉ុន្មានឆ្នាំចុងក្រោយនេះរាជរដ្ឋាភិបាលកម្ពុជា ក្រោមហេតុផលអភិវឌ្ឍន៍ តែងតែលេចឮសម្លេង ស្រែកទ្រហោយំរបស់ប្រជាពលរដ្ឋនៃតំបន់អភិវឌ្ឍទាំងនោះជារឿយៗ មានន័យថាអភិវឌ្ឍន៍កន្លែងណាប្រជាពលរដ្ឋវេទនាកន្លែងនោះ។

ជាការពិតការផ្តល់នូវដីសម្បទានសេដ្ឋកិច្ច គឺជាគម្រោងអភិវឌ្ឍន៍មួយ ដែលដើរតួនាទីសំខាន់ ក្នុងការជួយឲ្យជីវភាពប្រជាពលរដ្ឋមានភាពប្រសើរឡើង ពោលគឺកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ពាក់ព័ន្ធដល់ការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះបើយើងបែរទៅមើលអាជ្ញាធរវិញជាទូទៅអាជ្ញាធរមិនបានបំពេញកាតព្វកិច្ចជូនប្រជាពលរដ្ឋទាល់តែសោះ។ ជាពិសេស អាជ្ញាធរដែលកើតចេញពីពលរដ្ឋៗជាអ្នកបោះឆ្នោតឲ្យជាអ្នកផ្តល់សម្លេងឲ្យតែផ្ទុយអំពីនេះ នៅពេលដែលមានបញ្ហាក្នុងរឿងដីសម្បទានសេដ្ឋកិច្ចទាក់ទងដីធ្លីរបស់ប្រជាពលរដ្ឋដែលត្រូវក្រុមហ៊ុនរំលោភយក ដោយសារការអភិវឌ្ឍន៍ ត្រូវបណ្តេញប្រជាពលរដ្ឋចេញដោយពុំទាន់ទាំងមានសំណងសមរម្យ ឬមានការចរចាគ្នាផង អាជ្ញាធរតែងតែឈរនៅខាងក្រុមហ៊ុន ធ្វើបាបប្រជារាស្ត្រខ្លួនឯងទៅវិញ ហើយមិនតែប៉ុណ្ណោះ តែងតែរិះរកមធ្យោបាយ ដូចជាយកសារាចរ ស.ជ.ណ មកគាបសង្កត់រាស្ត្រឲ្យបាក់ស្មារតីលែងហ៊ានធ្វើការតវ៉ា ដោយចោទពលរដ្ឋថាជាពលរដ្ឋរស់នៅខុសច្បាប់ ហើយពួកគេគេមានច្បាប់មាន ស.ជ.ណ កុំតតាំងជាមួយគេ ហើយមានពលរដ្ឋជាច្រើនត្រូវឈ្នួញឃុបឃិតជាមួយអាជ្ញាធរ ចាប់ពលរដ្ឋខ្លួនឯងដាក់ពន្ធនាគារដណ្តើមយកដីក៏មាន។



ឧទាហរណ៍ ដូចជាករណីវិវាទដីធ្លីនៅបុរីកីឡា បឹងកក់ និងនៅបណ្តាខេត្តមួយចំនួនអាជ្ញាធរបែរជាចោទរាស្ត្រថា ជាអ្នករំលោភយកដីក្រុមហ៊ុន ជាក្រុមអនាធិបតេយ្យ ដោយពុំបានដោះស្រាយជូនពួកគាត់ឲ្យបានល្អនោះទេ គិតធ្វើយ៉ាងណាឲ្យតែឈ្នះទោះត្រូវចាប់ខ្លួនទាំងមិនមានកំហុស និងរកលេសចោទប្រកាន់តាមវិធីផ្សេងៗទៀត ដើម្បីធ្វើឲ្យរាងចាលលែងហ៊ានតវ៉ា។ ដូច្នេះការធ្វើបែបនេះធ្វើឲ្យពាក្យថា ការផ្តល់សម្បទានដី សម្រាប់ធ្វើការអភិវឌ្ឍន៍ ដើម្បីជាប្រយោជន៍ដល់ប្រជាជន និងប្រែទៅជាមានន័យផ្សេងទៅវិញហើយ គឺមានន័យថាការអភិវឌ្ឍន៍ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន និងធ្វើឲ្យរាស្ត្រកាន់តែក្រីក្រថែមទៀត ដោយមិនបានផ្តល់ប្រយោជន៍អ្វីទាល់តែសោះពីការអភិវឌ្ឍន៍៕

# ការវិភាគនយោបាយ ត្រូវការកម្រិតបែបណា ?

*នៅក្នុងការគ្រប់គ្រងប្រទេសនីមួយៗ ចាំបាច់ត្រូវមានគោលនយោបាយ នៅក្នុងការដឹកនាំ និងគ្រប់គ្រងរដ្ឋ ដែលជាមូលដ្ឋានចាំបាច់ ក្នុងការអភិវឌ្ឍន៍សង្គមជាតិ ឲ្យឆ្ពោះទៅកាន់របបគ្រប់គ្រងដែលប្រទេសនោះបានប្រកាន់យក។*

ជាមួយគ្នានេះដែរ ការសម្រេចបាននូវគោលនយោបាយប្រទេស គឺបានមកពីការរៀបចំគោលនយោបាយ របស់គណបក្សដែលឈ្នះឆ្នោត និងគណបក្ស ដែលមានសម្លេងបន្ទាប់ដែលបានចូលរួមបង្កើតរដ្ឋាភិបាលចម្រុះហើយរដ្ឋាភិបាលត្រូវអនុវត្តការងារទៅតាមគោលនយោបាយនោះនៅក្នុងអាណត្តិរបស់ខ្លួនផងដែរ។

ជាការល្អប្រសើរណាស់ ដែលចាំបាច់ប្រទេសនីមួយៗ មានគោលនយោបាយរបស់ខ្លួនដែលវិវត្តន៍មកពីគោលនយោបាយរបស់គណបក្ស ហើយគោលនយោបាយបក្សតែងមានភាពយូរអង្វែង សម្រាប់ធ្វើការឃោសនាស្វែងរកសន្លឹកឆ្នោតពីប្រជាពលរដ្ឋ ឲ្យពលរដ្ឋមានជំនឿទុកចិត្តបោះឆ្នោតឲ្យ ព្រោះគោលនយោបាយនេះ នឹងផ្តល់ភាពសុខសាន្ត ការរីកចម្រើនអភិវឌ្ឍន៍ដល់ពលរដ្ឋទូទៅ មិនមែនសំដៅបម្រើឲ្យតែប្រយោជន៍ នៃគណបក្សណាមួយនោះឡើយ ពោលគឺសំដៅបម្រើផលប្រយោជន៍ជាតិជាធំជាចម្បង។

ប៉ុន្តែអ្វីដែលជាសំខាន់នោះ គោលនយោបាយបក្ស ត្រូវតែមានការគាំទ្រពីសមាជិកសមាជិកានៃគណបក្សខ្លួន ដោយមានការចូលរួមពីមហាជន គ្រប់ជាន់ថ្នាក់ និងមានវិសាលភាពជាមួយនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិផងដែរ ដែលហេតុនេះហើយទើបបានជាគេឃើញថាកាពាក់ព័ន្ធនឹងការងារនយោបាយ តែងមានអ្នកនាំពាក្យ របស់គណបក្សនយោបាយនីមួយៗ ដើម្បីបំភ្លឺនូវរឿង ដែលពាក់ព័ន្ធការងារនយោបាយគណបក្ស និងកុំឲ្យខុស ឬប្រាសចាកពីគោលនយោបាយគណបក្ស វានាំឲ្យខូចកេរ្តិ៍ឈ្មោះ និងបាត់បង់ជំនឿទុកចិត្តពីប្រជាពលរដ្ឋ ដែលវាជាការខូចប្រយោជន៍ធំណាស់។

អ្វីដែលជាបញ្ហា នៅក្នុងសង្គមកម្ពុជាវិញនោះ ពាក់ព័ន្ធនយោបាយគឺរឿងដែលកើតមាននូវការវិភាគនយោបាយ ដែលគណបក្សតែងតែមានការប្រកួតប្រជែងគ្នា ដោយពុំគិតពីគណបក្សដទៃ ហើយដើម្បីប្រយោជន៍ផ្ទាល់គណបក្ស គេហ៊ានធ្វើអ្វីៗទាំងអស់ដើម្បីឲ្យគណបក្សមួយទៀតចាញ់ដោយអាប់មុខ ហើយគេធ្វើឲ្យគណបក្សគេឈ្នះគឺឈ្នះដោយភ្លូកទឹកភ្លូកដី។ ជាការពិតការប្រកួតប្រជែងគ្នា រវាងគណបក្សនយោបាយត្រូវតែកើតមាន ជាពិសេសនាពេលឃោសនាបោះឆ្នោត ប៉ុន្តែគេត្រូវមានក្រមសីលធម៌របស់ខ្លួន ឬរបស់គណៈកម្មការរៀបចំការបោះឆ្នោត ដើម្បីកុំឲ្យមានការប្រើពាក្យមិនពិរោះស្តាប់ ឬពាក្យអសុរោះ ពាក្យប្រមាថដែលពុំគួរគប្បីយកមកប្រើនោះឡើយ។ ពោលចង់មិនចង់ គេត្រូវតែយកគោលនយោបាយរបស់គណបក្ស ដែលគេចង់ទិតៀននោះមកមើល និងធ្វើការវិភាគថ្លឹងថ្លែងបង្ហាញទៅមតិសាធារណជន ឲ្យគេបានឃើញនិងយល់ថាគណបក្សនោះបានប្រព្រឹត្តិខុសពីគោលនយោបាយគណបក្សរបស់គេពិតមែន ហើយគេបានចែងគោលនយោបាយដើម្បីបោកប្រាសពលរដ្ឋតែប៉ុណ្ណោះ។ តែគេក៏មានសំណួរសួរថា តើនរណាជាអ្នកវិភាគនយោបាយ?តើអ្នកវិភាគនយោបាយ គួរតែមានកម្រិតយល់ដឹងនយោបាយបែបណា?

នៅក្នុងប្រទេសជឿនលឿន ការវិភាគនយោបាយ គេមិនដែលយកអ្នក ដែលត្រឹមតែមានព័ត៌មាននយោបាយនៅក្នុងដៃ មិនមែនយកអ្នកដែលមានតែវោហាស័ព្ទ មិនមែនអ្នកដែលមានងារជាឯកឧត្តម មិនមែនអ្នកដែលត្រឹមតែចេះ និយាយប្រខាងនយោបាយឲ្យមកធ្វើការវិភាគនយោបាយ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយដ៏ល្បីៗរបស់ជាតិ ឬឯកជនណាមួយនោះទេ ពីព្រោះដូចយើងបាននិយាយខាងដើមមកស្រាប់ អំពីបញ្ហានយោបាយ ហើយប្រជាពលរដ្ឋគេ ក៏មានការចេះដឹងជាបង្គួរខាងផ្នែកនយោបាយនេះ ភាគច្រើនផងដែរ។

ពោល អ្នកដែលវិភាគនយោបាយនេះ ដែលយ៉ាងហោចណាស់ ក៏ជាអ្នកមានកម្រិតសិក្សាផ្នែកវិទ្យាសាស្ត្រនយោបាយ ឬជាអ្នកមានមុខមាត់ ធ្លាប់ប្រឡូកខាងនយោបាយល្អមគួរសម ដែលគេទទួលស្គាល់ក្នុងសង្គមផងដែរ ពីព្រោះ អ្នកវិភាគនយោបាយទាំងនោះនិយាយអំពីបញ្ហានយោបាយ តែងមានទ្រឹស្តីនយោបាយ(បែបសង្គមនិយម,បែបសាធារណរដ្ឋ,បែបប្រជាធិបតេយ្យ) គួបផ្សំនិងការវិវត្តន៍ទាំងគ្រប់ផ្នែកក្នុងសង្គម( វិស័យនយោបាយ វិស័យទេសចរណ៍  វិស័យពាណិជ្ជកម្ម និងសេដ្ឋកិច្ច។ល។) មកច្របាច់បញ្ចូលគ្នា បើនិយាយមិនសមស្របនិងទ្រឹស្តីនយោបាយ មតិសាធារណជន ឬពលរដ្ឋគេនឹងសើចរយៈមាត់ជាមិនខានពីព្រោះពលរដ្ឋគេ មានចំណេះដឹងផ្នែកនយោបាយខ្ពស់ គេយល់ គេហ៊ានថាឲ្យនិងរិះគន់អ្នកវិភាគនោះភ្លាមៗ ដូច្នេះអ្នកដែលឡើងមកវិភាគ មិនជាចង់ឡើងមកលេចមុខលេចមាត់ក្នុងប្រព័ន្ធផ្សព្វផ្សាយប៉ុន្មានទេ ហើយការបកស្រាយរបស់គេ ក៏មិនមានន័យបង្កាច់បង្ខូច ឬបន្តុះបង្អាប់គោលនយោបាយ របស់គណបក្សដទៃ ឬបុគ្គលណាមួយដែរ ។

តែចម្លែកអីតែប្រទេសយើង ដាក់ស្រាសតែមួយតយ ក៏អាចវិភាគនយោបាយបានដែរ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយវិញ ត្រឹមតែជាអ្នកនិយាយនយោបាយទេ តែធ្វើដូចជាអ្នកវិភាគនយោបាយអ៊ីចឹង គេឃើញតែអ្នកមានកម្រិត អ្នកមានព័ត៌មាននយោបាយនៅក្នុងដៃជាអ្នកដែលមានតែវោហាស័ព្ទ ឬអ្នកដែលត្រឹមតែចេះ និយាយប្រខាងនយោបាយ មកឲ្យនិយាយ អ្នកដែលមានកម្រិតសិក្សាខាងនយោបាយ អ្នកដែលធ្លាប់ប្រឡូកខាងនយោបាយគេមិនឲ្យមកនិយាយទេ មិនដែលឲ្យចេញមុខក្នុងប្រព័ន្ធផ្សព្វផ្សាយតែម្តង។ ការនិយាយនោះ

ទៀតសោត ក៏ច្រើននិយាយតែពាក្យបង្កាច់បង្ខូច ឬបន្ទុះបង្អាប់ បុគ្គលអ្នកនយោបាយតែម្តង ព្រោះពុំមានអ្វីនិយាយ និងពុំមានកម្រិតយល់ដឹងខាងផ្នែកនយោបាយ។

ដូច្នេះបញ្ហានយោបាយមិនមែនអ្នកល្ងង់ៗ ឬអ្នកអធិប្បាយទូរទស្សន៍ អាចវិភាគបាននោះទេ៕




# អាដហុក ជាសមាជិកគណៈកម្មាធិការប្រព្រឹត្តកម្ម (CHRAC) បង្កើតកម្មវិធីដោះស្រាយ ទំនាស់ក្រៅប្រពន្ធ័តុលាការចាប់តាំងពីឆ្នាំ២០១៣

*ដោយយល់ឃើញថាពលរដ្ឋកម្ពុជាភាគច្រើនមានជីវភាពក្រីក្រពុំមានលទ្ធភាពក្នុងការតវ៉ាក្តី នៅពេលដែលមានជម្លោះដីធ្លីកើតឡើង ពោលគឺការរៀបចំនូវឯកសារវត្ថុតាង ដូចជាប័ណ្ណកម្មសិទ្ធិ ការចុះបញ្ជីដីធ្លី ឬអត្តសញ្ញាណអ្វីដែល ពួកគេមានគឺពួកគេ(ពលរដ្ឋ) អត់បានគិតគូរដល់ឯកសារទាំងនោះឡើយ ជារួមគឺពួកគេខ្វល់ តែម្យ៉ាង ជីវភាពប្រចាំថ្ងៃរបស់ពួកគេតែប៉ុណ្ណោះជាហេតុធ្វើឲ្យការដោះស្រាយជម្លោះ តាមប្រពន្ធ័តុលាការ គ្មានសង្ឃឹមថាឈ្នះ ឬមានយុត្តិធម៌ទេសំរាប់អ្នកក្រីក្រនៅកម្ពុជា។*

ក៏ប៉ុន្តែការដោះស្រាយបញ្ហា នៅក្នុងសង្គម ពិតមែនតែតម្រូវការ ការដោះស្រាយបញ្ហាត្រូវប្រើប្រាស់តាមប្រព័ន្ធច្បាប់វាជាការល្អប្រសើរ ឬប្រយោជន៍នាំសង្គមជាតិឲ្យឆ្ពោះទៅរកការប្រកាន់យកនីតិរដ្ឋ តែការដោះស្រាយបញ្ហាមួយចំនួន អាចប្រព្រឹត្តិឡើងក្រៅប្រព័ន្ធច្បាប់ ក៏គេអាចទទួលលទ្ធផលបានល្អប្រសើរផងដែរ ដែលគេឲ្យឈ្មោះថាការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ។

ដោយសារការឆ្លុះបញ្ចាំងនូវបញ្ហាដីធ្លី នាពេលកន្លងមក និងបច្ចុប្បន្នសមាគមអាដហុក ក៏បានយល់ឃើញថាដើម្បីជួយដល់អ្នកក្រីក្រ ដែលរងគ្រោះពីបញ្ហាដីធ្លីនេះ សមាគមអាដហុកក៏បង្កើតកម្មវិធីការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនេះឡើងក្នុងគោលបំណង:

- ធ្វើការពង្រឹងយន្តការដោះស្រាយទំនាស់ក្រៅប្រពន្ធ័តុលាការ។
- កសាងទំនាក់ទំនងពិភាក្សា និងបង្កើតកិច្ចសហប្រតិបត្តិរវាងអាជ្ញាធរ និងសហគមន៍។

នៅក្នុងកម្មវិធីដោះស្រាយទំនាស់នេះជាកម្មវិធីថ្មីដែលត្រូវបានសមាគមអាដហុកត្រៀមរៀបចំតាំងពីចុងឆ្នាំ២០១២មក ហើយក៏បានបង្កើតជាយន្តការសកម្មភាព នៅដើមឆ្នាំ២០១៣នេះ សម្រាប់ធ្វើសកម្មភាពទៅលើបណ្តាខេត្តមួយចំនួនដែលមានជម្លោះដីធ្លីច្រើន។នៅក្នុងកម្មវិធីដោះស្រាយទំនាស់ក្រៅប្រពន្ធ័តុលាការនេះទៀតសោត សមាគមក៏បានរៀបចំនូវការផ្សព្វផ្សាយតាមសៀវភៅផ្ទត់ និងឯកសារ ឧបករណ៍ដោះស្រាយទំនាស់ ដែលចង្អុលបង្ហាញពីតំណាក់កាល និងរបៀបនៃការដោះស្រាយបញ្ហាតាមរយៈក្រៅប្រព័ន្ធតុលាការ ដែលការដោះស្រាយនោះមានគុណសម្បត្តិ និងគុណវិបត្តិរបស់វាផងដែរ។

នៅក្នុងតំណាក់កាលនៃការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ គឺៈ

ទី០១ «**ការជួប**»ជាសិក្សាទំនាស់ ដោយប្រមូលព័ត៌មាន និងបញ្ចុះបញ្ចូលភាគីឲ្យចូលរួមដោះស្រាយ។

ទី០២ «**ការផែដកពិភាក្សា**» ជាការលើកទឹកចិត្តភាគីដោះស្រាយ ដោយផ្អែកលើផលប្រយោជន៍ ដឹកនាំភាគីក្នុងកិច្ចពិភាក្សាពេលមានភាពតានតឹង ឲ្យផ្លាស់ប្តូរគំនិត។

ទី០៣ «**ការចែករំលែក**»ជាការបង្ហាញពីផលវិបាកច្បាប់ និងសង្គម ដោយធ្វើយ៉ាងណាដើម្បីឲ្យគូរភាគីផ្ដល់សម្បទានឲ្យគ្នាទៅវិញទៅមក។

ទី០៤ «**ការសម្រេចចិត្ត**» ជាការធ្វើឲ្យមានការចូលរួមដោះស្រាយដោយភាគីទីបី និងរក្សាបាននូវអព្យាក្រឹតភាពក្នុងការជួយ ឲ្យមានការសម្រេចចិត្តប្រកបដោយយុត្តិធម៌។

ទី០៥ «**កិច្ចព្រមព្រៀង**»ជាការអនុវត្តន៍ ដែលមានឯកសារមានសាក្សី កិច្ចព្រមព្រៀង ដោយសរសេរជាលាយល័ក្ខអក្សរជាផ្លូវការ។

ដូច្នេះឯកសារ ឧបករណ៍ដោះស្រាយទំនាស់ក្រៅប្រពន្ធ័តុលាការ អាចជាវិភាគទានមួយសំរាប់ជួយដល់ដំណើរការដោះស្រាយទំនាស់ក្រៅប្រពន្ធ័តុលាការប្រកបដោយការគោរពសិទ្ធិមនុស្ស ច្បាប់ និង គោលការណ៍យេនឌ័រ ពិសេសទៅទៀត នៅគ្រប់ឧបករណ៍ទាំងអស់ក្នុងជំហានទាំងប្រាំ រាល់ការព្រមព្រៀងណាមួយរបស់គូភាគី គឺសុទ្ធសឹងតែកើតឡើងពីការស្ម័គ្រចិត្ត និង គ្មានការបង្ខិតបង្ខំឡើយ។

មិនតែប៉ុណ្ណោះ ឧបករណ៍នេះក៏មានការរួមបញ្ចូលនូវយន្តការដោះស្រាយផ្សេងៗ ដូចជា:ការសម្រុះសម្រួល ការផ្សះផ្សា និងមជ្ឈត្តវិនិច្ឆ័យ(អាជ្ញាកណ្ដាល)ផងដែរ ប៉ុន្តែមជ្ឈត្តវិនិច្ឆ័យនៅក្នុងឧបករណ៍នេះមិនដូចគ្នាទេទៅនឹងមជ្ឈត្តវិនិច្ឆ័យជាផ្លូវការ របស់ស្ថាប័នរដ្ឋនោះទេ៕

# ដាក់ទោសមន្ត្រីរាជការពាក់ព័ន្ធអំពើពុករលួយ ត្រូវគិតប្រាក់បៀវត្សសិន !

*អង្គភាពប្រឆាំងអំពើពុករលួយ បង្កើតឡើងក្នុងគោលបំណងលើកកំពស់ប្រសិទ្ធភាពសេវាគ្រប់បែបយ៉ាង ពង្រឹងអភិបាលកិច្ច និងនីតិរដ្ឋនៅក្នុងការដឹកនាំ និងការគ្រប់គ្រងរដ្ឋ ព្រមទាំងរក្សាភាពស្អាតស្អំយុត្តិធម៌ ដែលជាមូលដ្ឋានចាំបាច់ ក្នុងការអភិវឌ្ឍន៍ជាតិនិងកាត់បន្ថយភាពក្រីក្រ ដោយអនុវត្តទៅតាមច្បាប់ប្រឆាំងអំពើពុករលួយ៩ជំពូកនិង៥៧មាត្រា ហើយច្បាប់នេះក៏បានប្រកាសដាក់ឲ្យប្រើរួចរាល់ដែរ។*

ជាមួយគ្នានេះដែរច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយក៏មានគោលដៅប្រឆាំងអំពើពុករលួយ តាមការចាត់វិធានការ អប់រំទប់ស្កាត់ និងអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ ដោយមានការចូលរួមពីមហាជន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ហើយមានវិសាលភាពចំពោះ អំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់ក្រោយពេលច្បាប់នេះមានអានុភាពអនុវត្ត។ ចំណែកបទល្មើស និងទោសទណ្ឌ ក៏មានចែងបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌ ដែលមានកំណត់ទោសធ្ងន់ ឬស្រាលតាមប្រភេទនៃបទល្មើសទាំងនោះផងដែរ។

ជាការល្អណាស់ ដែលយើងមានច្បាប់សម្រាប់អនុវត្តនៅក្នុងប្រទេសរបស់យើង ព្រោះថានៅក្នុងការស្រាវជ្រាវចំណាត់ថ្នាក់ខាងអំពើពុករលួយនេះ នៅលើពិភពលោក ទោះបីជាបានប្រកាសនាពេលថ្មីៗនេះថាមានប្រទេសតែ១៨ទេ ដែលជាប់ជាប្រទេសមានអំពើពុករលួយជាងគេ តែសម្រាប់ប្រទេសកម្ពុជាយើង គឺមានលេខរៀងដល់ទៅទី១៨៣ឯណោះ។

អ្វីដែលជាបញ្ហា នៅក្នុងរឿងដែលកើតមានអំពើពុករលួយនេះ គឺការកេងប្រវ័ញ្ចពុំចេះឆ្អែតឆ្អន់របស់មនុស្សគ្រប់រូប ដែលតែងតែចង់មានចង់បានប្រជែងគ្នា ដោយពុំគិតពីអ្នកដទៃ ហើយដើម្បីប្រយោជន៍ផ្ទាល់ខ្លួន គេហ៊ានធ្វើអ្វីៗទាំងអស់។ នេះសម្រាប់អ្នកមានខ្លះ ដែលធ្វើធំហើយឆ្លៀតរកស៊ីកេងបន្លំ គេចពន្ធ ផលិតរបស់ក្លែងក្លាយ សូកប៉ាន់សមត្ថកិច្ច មិនឲ្យធ្វើ



ការត្រួតពិនិត្យដើម្បីចែកចាយទៅទីផ្សារ ដូចជាផលិតផលសំអាង ផលិតផលសម្រាប់បរិភោគ និងគ្រឿងញៀនជាដើម ដោយពុំគិតពីគ្រោះថ្នាក់ដល់សុខភាពមនុស្ស ដល់សង្គមជាតិ ឬដល់ក្មេងជំនាន់ក្រោយនោះឡើយ នេះជាបញ្ហាមួយដែលនិយាយទៅលើគ្រឿងប្រើប្រាស់ និងគ្រឿងបំពុលសង្គម និងយុវវ័យ។

ប៉ុន្តែអ្វីដែលចាំបាច់ទៅទៀតនោះ គឺបញ្ហាប្រាក់ខែមន្ត្រីរាជការ ដែលរាជរដ្ឋាភិបាលបានកំណត់នោះ បើយកមកចំណាយលើគ្រួសារក្នុងការដោះស្រាយជីវភាពប្រចាំថ្ងៃ មិនអាចដោះស្រាយជីវភាពបាននោះទេ។ ឧទាហរណ៍ប្រាក់ខែមន្ត្រីក្រុមប្រឹក្សាឃុំម្នាក់បានប្រហែលជាង១០ម៉ឺនរៀល ចំណែកកូន និងប្រពន្ធប្រមាណ៥ពាន់ ឬ៦ពាន់រៀលតែប៉ុណ្ណោះ សួរថាប្រាក់ខែ ដែលរាជរដ្ឋាភិបាលបានកំណត់ បើកឲ្យមន្ត្រីរាជការខ្លួននោះអាចចំណាយបានគ្រប់គ្រាន់ដែរឬអត់? ហើយទាំងអស់គ្នាក៏ដឹងដែរថា ប្រាក់ខែមួយខែៗចំណាយតែខ្លួនឯងម្នាក់ មិនគ្រាន់ផង ចុះទម្រាំកូន និងប្រពន្ធបានស្អីស៊ី?

ដូច្នេះហើយ ទើបមានការនិយាយថាបើមិនរកថែម ឬកេងប្រវ័ញ្ច ទទួលសំណូកតើបានស្អីស៊ី?ចំណែកអង្គភាពប្រឆាំងអំពើពុករលួយជឿដែរឬអត់ថាមន្ត្រីទាំងនោះមិនពុករលួយ? ចំណុចទាំងនេះមន្ត្រីរាជការទាំងអស់ក៏បានដឹងគ្រប់គ្នា ថាកូន ប្រពន្ធរបស់គាត់ គឺស៊ីមិនគ្រប់ទេ ចំពោះប្រាក់ខែរដ្ឋដែលកំណត់មក មិនតែប៉ុណ្ណោះប្រាក់ខែរបស់ពួកគាត់ ក៏ត្រូវចំណាយក្នុងមួយខែៗទៅលើការបង់សេវាថ្លៃទឹក ភ្លើង សំរាម បង់វិទ្យាល័យ មហាវិទ្យាល័យសម្រាប់កូន ពេទ្យ ទាំងអស់នេះសុទ្ធតែពុំមានការគាំពារពីរដ្ឋ ប៉ុន្តែទីផ្សារជាទីផ្សារសេរី ឯប្រាក់ខែជាប្រាក់សល់ពីរបបកុម្មុយនីស្ត យកមកធ្វើជាប្រាក់បៀវត្សរ៍នោះ? រឿងអីដែលគាត់មិនរកបន្ថែម? ចុះបើគាត់ឆ្លៀតរកបន្ថែម តើអាចចាត់ទុក ឬចោទពួកគាត់(មន្ត្រីរាជការ)ថាពុករលួយបានដែរឬអត់?

យើងនិយាយនេះមិនសំដៅការពារអំពើពុករលួយទេ តែវាមានផលប៉ះពាល់ខ្លះដែលយើងត្រូវលើកមកនិយាយដែរព្រោះមន្ត្រីរាជការមួយចំនួន ពួកគាត់មិនខ្វល់ទៅនឹងបញ្ហានេះប៉ុន្មានទេ គឺគាត់ខ្វល់តែពី រឿងរកអ្វីមកផ្គត់ផ្គង់ជីវភាពតែប៉ុណ្ណោះ។

មន្ត្រីរាជការក្រសួងអប់រំម្នាក់ សុំមិនបញ្ចេញឈ្មោះបាននិយាយថាពាក់ព័ន្ធនឹងប្រាក់ខែកូន និងប្រពន្ធរបស់គាត់ ដែលតិចតួចពេក ហើយតម្លៃរត់ការលិខិតស្នាមថ្លៃពេក គាត់សុខចិត្តមិនយកប្រាក់ខែប្រពន្ធ និងកូនទេ។ ប៉ុន្តែបើនិយាយទៅតាមផ្លូវច្បាប់វិញ វាជារឿងខុសច្បាប់ដែលគ្រប់គ្នាបានដឹងដែរថា ការប្រព្រឹត្តអំពើពុករលួយ វាជាអំពើខុសច្បាប់ គឺត្រូវតែមានការផ្តន្ទាទោស ហេតុនេះយើងចង់បង្ហាញថាប្រសិនបើចង់ដាក់ទោសមន្ត្រីរាជការថាប្រព្រឹត្តអំពើពុករលួយ គេត្រូវគិតគូរដល់ប្រាក់ខែ របស់ពួកគាត់សិនដែរទើបវាទូទាត់គ្នាបាន។ ពោលគឺទាល់តែមន្ត្រីរាជការទាំងនោះ មានប្រាក់ខែសមរម្យជាងសព្វថ្ងៃនេះទើបប្រសើរ ដែលធ្វើឲ្យការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយមានប្រសិទ្ធភាព។

ដូច្នេះការអនុវត្តច្បាប់ ទៅលើមន្ត្រីប្រព្រឹត្តអំពើពុករលួយនាពេលបច្ចុប្បន្ននេះ គឺបានទៅលើតែមន្ត្រីមួយចំនួនដែលល្បីថាខូចពេក កេងប្រវ័ញ្ចលើគោកពេក ទើបបានជាអង្គភាពប្រឆាំងអំពើពុករលួយ លេងអ្នកទាំងនោះ ដើម្បីជាការព្រមានដល់អ្នកដទៃទៀតឲ្យចេះ ដើម្បីរស់បានយូរ សមដូចពាក្យស្លោករបស់អង្គភាពប្រឆាំងអំពើពុករលួយបានបញ្ជាក់ថា មិនចង់ពុករលួយ មិនអាចពុករលួយ មិនហ៊ានពុករលួយ។៕

# ហេតុអ្វីត្រូវការចាំបាច់ធុរកិច្ច និងសិទ្ធិមនុស្ស!

*គោលការណ៍ណែនាំស្តីពី«ធុរកិច្ចនិងសិទ្ធិមនុស្ស»ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិអនុម័តជាឯកច្ឆន្ទកាលពីថ្ងៃទី១៦ខែមិថុនាឆ្នាំ២០១១។ការអនុ ម័តនេះធ្វើឡើងដោយសារតែយោងទៅដល់សារៈសំខាន់នៃគោលការណ៍ណែនាំ ដែលវាគឺជាសំណុំនៃគោលការណ៍ចំនួន៣១ដែលគាំទ្រដល់ការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយរបស់អ.ស.ប។ជាដំបូងឯកសារនេះពុំទាន់បានចងភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់នៅឡើយទេទើបតែក្រុមប្រឹក្សា សិទ្ធិមនុស្សអង្គការសហប្រជាជាតិបានបង្កើតឲ្យគោលការណ៍នេះក្លាយទៅជាចំណុចយោងជាសកលសម្រាប់ការអនុវត្តន៍ ចំពោះធុរកិច្ចនិងសិទ្ធិមនុស្ស។*

គោលការណ៍ណែនាំនេះមានមូលដ្ឋានលើសរសរទ្រូងបីគឺការការពារ ការគោរព និងដំណោះស្រាយ ហើយក្របខ័ណ្ឌនៃគោលការណ៍នេះបានបង្ហាញថា៖

- រដ្ឋមានតួនាទីការពារប្រឆាំងនឹងការរំលោភ ដោយភាគីទីបី រាប់បញ្ចូលទាំងសហគ្រាសពាណិជ្ជកម្ម តាមរយៈគោលនយោបាយបទបញ្ញា និងសេចក្តីសម្រេច។

- ការទទួលខុសត្រូវ ក្នុងការគោរពសិទ្ធិមនុស្ស ដែលមានន័យថាសហគ្រាសពាណិជ្ជកម្មទាំងឡាយ គួរតែធ្វើសកម្មភាព ដោយយកចិត្តទុកដាក់ ជៀសវាងការរំលោភលើសិទ្ធិអ្នកដទៃ និងការដោះស្រាយផលប៉ះពាល់ធ្ងន់ធ្ងរពាក់ព័ន្ធដល់សកម្មភាពរបស់ខ្លួន។
- សេចក្ដីត្រូវការឲ្យទទួលបានការដោះស្រាយកាន់តែទូលាយសម្រាប់ជនរងគ្រោះ នៃអំពើរំលោភបំពានទាក់ទងនឹងធុរកិច្ច ទាំងតាមប្រព័ន្ធយុត្តិធម៌ និងក្រៅប្រព័ន្ធយុត្តិធម៌។

បើនិយាយឲ្យខ្លី និងងាយយល់ ធុរកិច្ចគឺជាគោលការណ៍សកល មានន័យថាជាកាតព្វកិច្ច ដែលនៅក្នុងបរិបទសិទ្ធិមនុស្ស ត្រូវបានធ្វើការពិគ្រោះយោបល់ យ៉ាងទូលំទូលាយ ដោយមានការចូលរួមពីសហគ្រាសពាណិជ្ជកម្ម សង្គមស៊ីវិលបុគ្គល និងសហគមន៍ដែលទទួលរងផលប៉ះពាល់។ចំណុចទាំងអស់នៃធុរកិច្ចត្រូវបានគូសបញ្ជាក់ អំពីវិធានការទាំងឡាយ ដែលរដ្ឋនានាបានចាត់ចែងឡើង ដើម្បីជំរុញឲ្យធុរកិច្ចគោរពសិទ្ធិមនុស្ស ផ្ដល់គម្រោងដល់ធុរកិច្ចទាំងឡាយឲ្យបានដឹង និងបង្ហាញឲ្យគេឃើញថា ពួកគេគោរពសិទ្ធិមនុស្ស និងកាត់បន្ថយហានិភ័យ នៃការបង្កឲ្យមាន ឬការរួមចំណែកធ្វើឲ្យអន្តរាយដល់សិទ្ធិមនុស្ស និងបង្កើតនូវខ្នាតរង្វាស់សម្រាប់អ្នកដែលពាក់ព័ន្ធ ដើម្បីវាយតម្លៃអំពីការគោរពសិទ្ធិមនុស្សរបស់ធុរកិច្ច។ គោលការណ៍ទាំងនេះក៏មានចែងអំពីអ្វី ដែលរដ្ឋ និងសហគ្រាសពាណិជ្ជកម្មគួរតែធ្វើ ដើម្បីឲ្យប្រសើរឡើង ដល់ការទទួលបាននូវដំណោះស្រាយ ប្រកបដោយប្រសិទ្ធភាព សម្រាប់បុគ្គលទាំងឡាយណា ដែលសិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន។

នៅក្នុងបរិបទប្រទេសកម្ពុជា ធុរកិច្ច និងសិទ្ធិមនុស្ស ត្រូវបានក្លាយទៅជាប្រធានបទសំខាន់ នៅក្នុងទិវាសិទ្ធិមនុស្ស ថ្ងៃទី១០ធ្នូ ហើយធុរកិច្ចអន្តរជាតិតំណាងឲ្យក្រុមមនុស្សដ៏សំខាន់ ដែលជាម្ចាស់ក្រុមហ៊ុនសហគ្រាសរោងចក្រដែលផលិតទំនិញ និងសេវាសម្រាប់សេដ្ឋកិច្ចមានតួនាទីសំខាន់ណាស់ក្នុងការអភិវឌ្ឍន៍ប្រទេស គេត្រូវការចាំបាច់ធុរកិច្ចក្នុងការអនុវត្តន៍ឲ្យបានខ្ជាប់ខ្ជួន នូវគោលនយោបាយដើម្បីទប់ស្កាត់បញ្ហាហើយសកម្មក្នុងការដោះស្រាយ ចំពោះផលអវិជ្ជមានជាសក្ដានុពល និងជាក់ស្ដែងដែលកើតឡើងពីសកម្មភាពរបស់ខ្លួន។

យ៉ាងណាមិញ ការលើកស្ទួយដល់សិទ្ធិមនុស្ស គេត្រូវនិយាយទៅដល់លក្ខខណ្ឌសិទ្ធិមនុស្សជាមុនសិន ហើយលក្ខខណ្ឌសិទ្ធិមនុស្សនោះអាចបញ្ជ្រាបបាន តាមរយៈមុខងារសាធារណៈ និងមុខងារឯកជន ដែលតាមរយៈមុខងារទាំងពីរនេះយើងអាចទទួលបាននូវអ្នកវិនិយោគ សហគ្រាសរោងចក្រឬក្រុមហ៊ុនដែលធ្វើការវិនិយោគ ដូចជាដីសម្បទានសេដ្ឋកិច្ចដែលមានទម្រង់ស្របទៅតាមស្តង់ដារអន្តរជាតិ មានការគោរពទៅតាមលក្ខខណ្ឌ បំពេញកាតព្វកិច្ចត្រឹមត្រូវ គោរពច្បាប់ប្រទេស ហើយយើងក៏ទទួលបានមកវិញនូវសុវត្ថិភាពការងារសម្រាប់កម្មករ កម្មការិនី ពុំមានការទាមទារតវ៉ា( ធ្វើកូដកម្ម បាតុកម្ម) ពុំមានការដួលសន្លប់ក្នុងការងារជាដើម។ល។ ផ្ទុយទៅវិញ ប្រសិនបើមានអធិករណ៍ទាំងនេះកើតឡើងចាំបាច់ត្រូវតែមានការដោះស្រាយឲ្យបានសមស្របអាចទទួលយកបានពោលគឺការដោះស្រាយទៅតាមផ្លូវច្បាប់ ឬលក្ខខណ្ឌ ព្រោះបើពុំដូច្នោះទេកម្មករនៅតែមានបញ្ហា ដោយសារតែការមិនគោរពច្បាប់ ហើយបាតុកម្មនៅតែកើតឡើងពុំឈប់ឈរ ពិសេសការដោះស្រាយដល់ជនរងគ្រោះដែលរងការរំលោភបំពាន ត្រូវតែធ្វើឡើងតាមប្រព័ន្ធយុត្តិធម៌ និងស្របទៅតាមលក្ខខណ្ឌការងារ ពីព្រោះបើមានបញ្ហាវិវាទកម្មករកើតឡើង (ដែលយើងឃើញមានការកើនឡើងក្នុងពេលបច្ចុប្បន្ន)មិនគួរបង្កើតកម្លាំងដើម្បីទប់គ្នា ដោយប្រើអំពើហិង្សា ដើម្បីយកឈ្នះយកចាញ់ដោយកម្លាំងបាយនោះឡើយ។ បន្ថែមលើនេះទៀតការជួយលើកស្ទួយលើផ្នែកសុខភាពក៏ជាចំណុចសំខាន់ក្នុងការអភិវឌ្ឍន៍ផងដែរ។

ជារួមការដែលយើងអាចបំពេញកិច្ចការទាំងនេះបានល្អប្រសើរនោះគឺយើងចាំបាច់ត្រូវមានការផ្សព្វផ្សាយ ឲ្យយល់ដឹងអំពីធុរកិច្ច ទើបគ្មានការរំលោភសិទ្ធមនុស្ស ហើយត្រូវបញ្ចៀស និងបញ្ឈប់នូវរាល់គម្រោងអភិវឌ្ឍន៍ឬសហប្រតិបត្តិការទាំងឡាយណាដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិមនុស្សធ្ងន់ធ្ងរ និងចាត់វិធានការដោះស្រាយជាបន្ទាន់ ចំពោះជនរងគ្រោះដែលរងផលប៉ះពាល់។ ត្រូវមានយន្តការតាមដាននូវធុរកិច្ច និងសិទ្ធិមនុស្ស និងគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការគោរពការពារសិទ្ធិមនុស្ស និងបន្តកិច្ចសហការជាមួយនឹងសង្គមស៊ីវិលក្នុងការចូលរួមទប់ស្កាត់ និងបញ្ចៀសអំពើរំលោភសិទ្ធិមនុស្សរួមមានសិទ្ធិពលរដ្ឋ នយោបាយ និងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ហើយការអាចអនុវត្តទៅបាន លុះត្រាណាតែយើងផ្ដល់លក្ខខណ្ឌដល់ធុរកិច្ចត្រូវមានការឆ្លងកាត់ការអនុម័តច្បាប់នេះដោយរដ្ឋសភាដើម្បីពិនិត្យឲ្យមានការយកចិត្តទុកដាក់ដើម្បីឲ្យធុរកិច្ចអនុវត្តឲ្យបានពេញលេញ៕វ



# ដកដី ផ្តល់ដី ជាជំនាញរបស់អ្នកនយោបាយ ?

*បញ្ហាដីធ្លីដែលកើតមាននៅប្រទេសកម្ពុជាគឺបង្ករឡើងដោយអ្នកមានឃុបឃិតគ្នាជាមួយអ្នកមានអំណាចដកហូត ឬបណ្តេញប្រជាពលរដ្ឋចេញដោយយោងលើសេចក្តីប្រកាស ស.ជ.ណ (សេចក្តីជូនដំណឹង) ដែលជាហេតុធ្វើឲ្យ នាយផ្ទក់ និង នាយផ្ទយ អត់ទ្រាំមិនបាននិយាយទៅគឺមិនអស់ចិត្តខ្លាចពលរដ្ឋកាន់ប្រទ្បំដោយអរគុណអ្នកដែលដេញ ដែលចាប់ខ្លួនដាក់គុករួចដោះលែងប្រគល់ដីរបស់ខ្លួនឲ្យវិញតែបែរជាដឹងគុណគេថែមទៀត។*

**នាយផ្លូយ៖** ផ្លក់! អ្នកនយោបាយបច្ចុប្បន្នគេថាកម្ពុជាកំពុងឈានទៅរកនីតិរដ្ឋ តែទង្វើរបស់គេបណ្តេញរាស្ត្រយកដីហេតុអ្វីបានជារាស្ត្រមិនអាចទាមទារនីតិរដ្ឋការពារទ្រព្យសម្បត្តិរបស់ខ្លួនឯងបាន?

**នាយផ្លក់៖** ផ្លូយ ឯងឆ្ងល់ធ្វើស្អី ! អាហ្នឹងហើយដែលគេហៅថាស៊ីតាមជំនាញនោះអី ព្រោះគេស៊ីបានតែចំពោះអ្នកក្រីក្រតែប៉ុណ្ណោះដោយពួកគេយល់ថាក្រុមអ្នកក្រីក្រភាគច្រើនមិនមានឯកសារគ្រប់គ្រាន់ដើម្បីការពារទ្រព្យសម្បត្តិពួកគេឡើយ។

**នាយផ្លូយ៖** ផ្លក់! នរណាក៏ដឹងដែរថាដីធ្លី ផ្ទះរបស់ពួកគាត់(ពលរដ្ឋ)រស់នៅតាំងពីឆ្នាំ១៩៧៩ ដោយមានរដ្ឋអំណាចទទួលស្គាល់មានប័ណ្ណគ្រួសារ សៀវភៅគ្រួសារមានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ ចុះហេតុអ្វីនៅពេលដែលរដ្ឋត្រូវការគេតែងចោទថាពលរដ្ឋរស់នៅមិនស្របច្បាប់?

**នាយផ្លក់៖** ចំណុចហ្នឹងហើយដែល គេហៅថាស៊ីតាមជំនាញនោះ តែផ្លូយឯងត្រូវចេះឆ្ងល់ថា បើពួកគេ (អ្នកមាន អ្នកមានអំណាច) ចោទពលរដ្ឋរស់នៅខុសច្បាប់ដូច្នេះ រដ្ឋអំណាចទាំងនោះក៏ខុសច្បាប់ដែរ។ បើយើងសង្កេតមើលទំនាស់ដីធ្លីដែលកើតមាននៅប្រទេសកម្ពុជាភាគច្រើនចេញពីអ្នកមានអំណាច ហើយអត់សូវមានក្រុមអ្នកក្រណាទៅរំលោភដីអ្នកមានឡើយ។

**នាយផ្លូយ៖** ផ្លក់! បើតាមគ្នាមើលសារព័ត៌មាន ឬស្តាប់វិទ្យុភាគច្រើនអ្នកដែលត្រូវគេរំលោភដីធ្លីសុទ្ធតែអ្នកក្រីក្រ ហើយអ្នកទាំងនោះមួយចំនួនត្រូវបានម្ចាស់ដីថ្មីប្តឹងម្ចាស់ចាស់ចាប់ដាក់ពន្ធនាគារប៉ុន្តែគ្នាអត់សូវឃើញអ្នកមានរំលោភដីអ្នកក្រហើយត្រូវអ្នកក្រប្តឹងទៅតុលាការត្រូវតុលារចាត់វិធានការចាប់ដាក់គុកនោះឡើយ។

**នាយផ្លក់៖** ប៉ុណ្ណឹងក៏ឆ្ងល់ដែរ ធ្វើមើលតែមនុស្សមិនដែលធ្លាប់រស់នៅស្រុកខ្មែរអ៊ីចឹង ពាក្យថានីតិរដ្ឋមានតែសម្រាប់អ្នកក្រីក្រទន់ខ្សោយតែប៉ុណ្ណោះ រីឯអ្នកមាន អ្នកមានអំណាចពួកគេមិនដែលខ្វល់នឹងនីតិរដ្ឋឡើយហើយមានពេលខ្លះអាបញ្ហាផ្ទាល់មាត់របស់ពួកគេដែលគេហៅថាអនុសាសន៍នោះវាសាហាវជាងច្បាប់ទៅទៀតដែលផ្លូយឯងគួរតែដឹងអំពីស្ថានភាពនៅស្រុកខ្មែរ។ អ៊ីចឹងហើយបានជាអ្នកធំឬអ្នកមានអំណាចដកដីពីរាស្ត្រហើយប្រគល់ដីរាស្ត្រឲ្យរាស្ត្រវិញគឺរាស្ត្រដឹងគុណអ្នកដែលរំលោភបំពានច្បាប់ដោយឥតដឹងខ្លួនព្រោះតែក្រីក្រ ហើយរាស្ត្រគ្មានឱកាស តវ៉ាតាមផ្លូវច្បាប់ជាមួយអ្នកមានថែមទៀត។ ដោយពេលវេលាខ្លីគ្នាគិតលាផ្លូយឯងត្រឹមនេះសិនចុះចាំជួបគ្នាលេខក្រោយទៀត។

កំប្លែង



# ឆ្កួតអំណាច

អាហារពេលល្ងាច នៃការជួបជុំរបស់ គ្រួសារមួយ បន្ទាប់ពីឈប់សំរាកចុងសប្តាហ៍។

**យាយ** ៖ ហ៊ឺ ! របបគ្រប់គ្រងបច្ចុប្បន្នសម្បូរក្មេងពាល ក្មេងទំនើង លេងល្បែង ផឹកស៊ី ស្រី ញី ដែលចាស់ពីដើមគេថា ឆ្កួតបី ៖

- ឆ្កួតទីមួយ ឆ្កួតស្រី
- ឆ្កួតទីពីរ ឆ្កួតស្រា
- ឆ្កួតទីបី ឆ្កួតល្បែងពាលា

ដែលឆ្កួតទាំងបីនេះធ្វើឲ្យសង្គមរីកររដោយសារ អ្នកមានអ្នកធំផឹកស៊ីបាញ់បោះលើសមត្ថកិច្ច ហើយអត់ហ៊ានអន្តរាគមន៍ ស្រួលមិនស្រួល អស់បុណ្យ អស់ស័ក្តិ ហេងស៊ុយជាប់គុក។

**ចៅ** ៖ យាយៗតាមចៅមើលឃើញមានឆ្កួតមួយទៀត !

**យាយ** ៖ ឆ្កួតអី អាចៅតាំងពីយាយកើតមក ឮមានតែប៉ុណ្ណឹង?

**ចៅ** ៖ ឆ្កួតអំណាច ណាលោកយាយ!

**យាយ** ៖ ឆ្កួតអំណាច ហ្នឹងវាយ៉ាងម៉េចអាចៅ ?

**ចៅ** ៖ ឆ្កួតអំណាច គឺចៅឃើញ អ្នកធំមួយចំនួន ខ្លះពិការទៅធ្វើការកាន់ឈើច្រត់ ខ្លះមានអ្នកគ្រា ពេលចៅឃើញពិបាកភ្នែកណាស់លោកអើយ ឆ្កួតនឹងអំណាចនោះ។

# អ្នកភូមិសង្គមថ្មីត្រូវការដីអភិវឌ្ឍន៍នៅកន្លែង

អ្នកភូមិសង្គមថ្មីត្រូវការដីអភិវឌ្ឍន៍នៅកន្លែងជម្លោះរវាងអ្នកសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិសាត់ ជាមួយក្រុមហ៊ុន MDS ចាប់តាំងពីឆ្នាំ ២០១០ បន្ទាប់ពីរដ្ឋាភិបាលបានផ្តល់សម្បទានដីសេដ្ឋកិច្ចទៅអោយក្រុមហ៊ុននេះ កន្លងមកមិនបានដោះស្រាយផលប៉ះពាលជូនពួកគាត់។

ពលរដ្ឋដែលរស់នៅតំបន់នោះភាគច្រើនជាអតីតកងទ័ពខ្មែរក្រហម ដែលធ្វើការផ្តាច់ខ្លួន ដែលកាលនោះគេហៅថាសមាហរណកម្ម។ ពួកគាត់បានកាន់កាប់រុករានដីក្នុងឆ្នាំ អំឡុង១៩៩៩-២០០០។ ការរស់នៅរបស់ពួកគាត់មានការទទួលស្គាល់ពីរដ្ឋអំណាច ភូមិ ឃុំ រហូតដល់ ស្រុក។ ចាប់តាំងពីក្រុមហ៊ុនទទួលបានសិទ្ធិសម្បទានដី វិវាទរវាងក្រុមហ៊ុន និងប្រជាពលរដ្ឋក៏កើតមានជាបន្តបន្ទាប់ កាលនោះមានពលរដ្ឋប្តឹងតវ៉ារហូតដល់ទៅ ៨៤ គ្រួសារ ប៉ុន្តែដោយតំបន់នោះជាតំបន់ដាច់ស្រយាល ហើយពលរដ្ឋមានការភយ័ខ្លាចពីការគំរាមកំហែង ផ្ទួបផ្សំទៅនឹងភាពក្រីក្រធ្វើអោយពួកគាត់បោះបង់ចោលការទាមទារតវ៉ា។

បច្ចុប្បន្ន បណ្តឹងរបស់ពួកគាត់នៅសល់ ២៣គ្រួសារ ដែលក្នុងនោះមានមួយគ្រួសារទទួលយកសំណង និងមួយគ្រួសារទៀតនៅក្រៅដីរបស់ក្រុមហ៊ុន ដូចនេះសល់តែ២១គ្រួសារ ដែលកាន់កាប់លើផ្ទៃដី អាស្រ័យផល និងមិនអាស្រ័យផល ជិត ២០០ហិកតា។

ក្នុងចំណោម២១គ្រួសារ យើងបានធ្វើសម្រង់តាមទម្រង់សលាកបត្រព័ត៌មាន លើកទី១បាន ៥គ្រួសារ, លើកទី២ បាន៨គ្រួសារ ក្នុងនោះក្រៅបណ្តឹង១, លើកទី៣ បានចំនួន៣ សរុប បានចំនួន ១៦គ្រួសារ នៅសល់ ៦គ្រួសារទៀតអត់ទាន់បំពេញ។បើតាមការបញ្ជាក់ពីលោក ហេង សុភាណា អភិបាលស្រុកវាលវែងថា ក្នុងចំណោម ២១ គ្រួសារ ១៦គ្រួសារ មានបណ្ណ័កម្មសិទ្ធិស្មើ ៣០ ក្បាលដី ដែលមានដី ទំហំ ១២,៨០ ហិកតា និង៥គ្រួសារទៀតអត់មានដី។ ពាក់ពន្ធ័និងសលាកបត្រ័ព័ត៌មាន នៅត្រង់ចំណុច កំណត់សំគាល់ ដែលដាក់ថា សលាកបត្រ័ព័ត៌មាននេះគឺ ជាឯកសារសំរាប់ពិនិត្យដោះស្រាយ គោលនយោបាយ សម្បទានសង្គមកិច្ចនោះ លោក **កើត ឆៃ** អភិបាលរងខេត្តពោធិសាត់បានបញ្ជាក់ថា ដីដែលពលរដ្ឋរស់នៅអាស្រ័យផលបច្ចុប្បន្ននោះ គឺស្ថិតក្នុងដែនជំរកសត្វព្រៃភ្នំសំកុស ដូច្នេះ បើចង់បានដីក្លាយជាកម្មសិទ្ធិទាល់តែសុំតាមរយៈសម្បទាសង្គមកិច្ចទើបបាន។

លោកបន្តទៀតថា លោកនឹងធ្វើការដោះស្រាយជាក់ស្តែងនៃការកាន់កាប់របស់ពួកគាត់ហើយលោកក៏ត្រៀមសម្រាប់អ្នកអត់ដីដែរ។

លោក **ខូយ រីដា** អភិបាលរងខេត្តពោធិសាត់បានបន្ថែមថា បើសិនការដោះស្រាយនេះបានជោគជ័យ អាជ្ញាធរនឹងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល បន្តដោះស្រាយនៅកន្លែងផ្សេងៗទៀត ក្នុងខេត្តពោធិសាត់។

ក្រុមអង្គការមិនមែនរដ្ឋាភិបាលបានស្វាគមន៍ទៅនិងចំណាត់ការរបស់អាជ្ញាធរខេត្តពោធិសាត់ ដែលបានយកចិត្ត ទុកដាក់ ដោះស្រាយជូនព្រជាពលរដ្ឋ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ត្រូវដោះស្រាយដោយយុត្តិធម៌គ្មានហិង្សា៕



# ការការពាររដ្ឋធម្មនុញ្ញដោយប្រើអំពើហិង្សា គឺជាការរំលោភសិទ្ធិមនុស្ស




ឧបត្ថម្ភដោយ

OXFAM

**គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា**

The Cambodian Human Rights Action Committee (CHRAC)

អាសយដ្ឋាន: ផ្ទះលេខ ៩Eo ផ្លូវលេខ: ៣៣០, ខណ្ឌចំការមន, ភ្នំពេញ | ទំនាក់ទំនងអ៊ីម៉េល: chracsecretariat@yahoo.com

ទូរស័ព្ទ: 023 301 415/ 023 305 609 | ទូរសារ: 023 218 759 | គេហទំព័រ: www.chrac.org

បោះពុម្ព ខែមីនា ឆ្នាំ២០១៥ | ចំនួន ៣០០០ច្បាប់